FIRST FINANCE

# ដៃគូដំណោះស្រាយ ហិរញ្ញវត្ថុផ្នែក លំនៅដ្ឋាន

របាយការណ៍ប្រចាំឆ្នាំ ២០១៧



# មាតិកា

០៤. សាររួមពី អគ្គនាយិកា និង ប្រធានក្រុមប្រឹក្សាភិបាល

០៦. អំពី ហ្វឺស ហ្វាយនែន

០៨. សមិទ្ធផលរបស់យើង

១០ អំពីផលិតផល

១១ តំបន់ប្រតិបត្តិការ

១២ ដៃគូវិនិយោគរបស់យើង

១៣ រចនាសម្ព័ន្ធ ហ្វឺស ហ្វាយនែន

១៤ ការអភិវឌ្ឍជាប្រចាំ

១៦. រឿងរបស់អតិថិជន

១៨. ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ

២២. របាយការណ៍របស់សវនករឯករាជ្យ

២៤. របាយការណ៍ហិរញ្ញវត្ថុ

២៨. រឿងរបស់អតិថិជន

៣០. ក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំ

តួរលេខក្នុងរបាយការណ៍នេះ គឺរបស់ ហ្វឺស ហ្វាយនែន សម្រាប់ការិយបរិច្ឆេទ ០១ មករា ២០១៧ ដល់ ៣១ ធ្នូ ២០១៧

# សាររួមពី អគ្គនាយិកា និង ប្រធានក្រុមប្រឹក្សាភិបាល



ហ្វីស ហ្វាយនែន បន្តចក្ខុវិស័យរបស់ខ្លួន ដើម្បីឱ្យប្រជាជនកម្ពុជាអាចសម្រេចក្តីសុបិនរបស់ពួកគេ ក្នុងការក្លាយជាម្ចាស់កម្មសិទ្ធិផ្ទះសម្បែង។ ជាស្ថាប័នមួយក្នុងចំណោមស្ថាប័នដ៏តិចតួច ដែលមានជំនាញក្នុងការផ្តល់ហិរញ្ញវត្ថុខ្នាតតូចផ្នែកលំនៅដ្ឋាន ការរៀនពីបទពិសោធន៍ និងបញ្ហាប្រឈមផ្សេងៗ គឺជាដំណើរការបន្តទៅមុខ។ ក្នុងឆ្នាំ២០១៧ ហ្វីស ហ្វាយនែន បានបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនលើការពង្រឹងផ្ទៃក្នុង ដែលកិច្ចការនេះ បានចាប់ផ្តើមតាំងពីឆ្នាំ២០១៦ ។ កិច្ចការទាំងនោះរួមមាន ការបង្កើតនាយកដ្ឋានបណ្តុះបណ្តាល និងអភិវឌ្ឍន៍ ដើម្បីផ្តោតលើការអភិវឌ្ឍជំនាញវិជ្ជាជីវៈរបស់បុគ្គលិក ការពិនិត្យជាទៀងទាត់លើដំណើរការ និងគោលនយោបាយឥណទាន និងការដាក់ឲ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានថ្មី។

ចំពោះទីផ្សារកម្ចីផ្នែកលំនៅដ្ឋាន ឆ្នាំ២០១៧ បង្ហាញពីនិន្នាការវិជ្ជមាន ក្នុងការសាងសង់ផ្ទះ ដែលមានតម្លៃសមរម្យ។ គម្រោងគេហដ្ឋានដែលមានតម្លៃសមរម្យធំៗចំនួនបីត្រូវបានសម្ពោធ ក្នុងឆ្នាំ២០១៧ ហើយគ្រោងនឹងបញ្ចប់មុនឆ្នាំ២០១៩ ។ នេះជាចំនួនបន្ថែមទៅលើគម្រោងតូចៗមួយចំនួនដែលផ្តោតតម្លៃសមរម្យ (តម្លៃចន្លោះពី ២០,000 ទៅ ៥០,000 ដុល្លារ) ខណៈនេះដែរ តម្រូវការគម្រោងខុនដូហាក់នៅមានកម្រិតទាបប្រៀបធៀបនឹងឆ្នាំកន្លងទៅ ។ម្ចាស់គម្រោងមួយចំនួនបានប្តូរចំណាប់អារម្មណ៍របស់ពួកគេទៅលើគ្រួសារមានចំណូលមធ្យម ដែលកំពុងស្វែងរកការរស់នៅប្រកបដោយបរិយាកាសល្អប្រណិត។

ខណៈដែលកម្ចីមិនដំណើរការនៅតែជាបញ្ហាប្រឈម ហ្វីស ហ្វាយនែន បានផ្តោតកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងឆមាសទីមួយលើការដោះស្រាយបញ្ហាមួយចំនួន ដែលរួមមាន ការកែសម្រួល និងបង្កើតដំណើរការ និងគោលនយោបាយថ្មីៗ ការបណ្តុះបណ្តាលបុគ្គលិកដែលទើបចូលថ្មី និងបុគ្គលិកចាស់លើដំណើរការ និងគោលនយោបាយថ្មីៗទាំងនេះ។ នៅឆមាសទីពីរ ក្រុមការងារបានផ្តោតលើកំណើនផលប័ត្រឥណទានប្រកបដោយគុណភាព។

ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានថ្មី គឺជាគម្រោងចម្បងមួយទៀតសម្រាប់ ហ្វីស ហ្វាយនែន ក្នុងការពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យរបស់ខ្លួន។ ក្នុងឆ្នាំ២០១៧ បន្ទាប់ពីពិនិត្យលើសំណើ ហ្វីស ហ្វាយនែន បានជ្រើសរើសយក Morakot VB ជាប្រព័ន្ធគ្រប់គ្រងព័ត៌មានគោលសម្រាប់ការគ្រប់គ្រងផលប័ត្រឥណទានរបស់ខ្លួន។ ប្រព័ន្ធគ្រប់គ្រងព័ត៌មានរួមមានលំហូរការងារដោយស្វ័យប្រវត្តិក្នុងដំណើរការអនុម័តឥណទាន រួមទាំងកម្មវិធីគ្រប់គ្រងអតិថិជនបន្ថែមទៅលើប្រព័ន្ធគ្រប់គ្រងឥណទានចាស់។ ប្រព័ន្ធគ្រប់គ្រងព័ត៌មានថ្មីនេះអាចឱ្យ ហ្វីស ហ្វាយនែន ធ្វើការសម្រេចចិត្តទាន់ពេល និងប្រសើរជាងមុន។

ហ្វីស ហ្វាយនែន ក៏មានមោទនភាពដែលត្រូវបានជ្រើសរើសជាស្ថាប័នមួយក្នុងចំណោមស្ថាប័នចំនួន ១០ ដែលបានជាប់ក្នុងវគ្គពាក់កណ្តាលផ្តាច់ព្រ័ត្រ សម្រាប់ពានរង្វាន់មីក្រូហិរញ្ញវត្ថុអឺរ៉ុប ក្នុងឆ្នាំ២០១៧ ដែលផ្តោតលើ "មីក្រូហិរញ្ញវត្ថុសម្រាប់លំនៅដ្ឋាន" ។ កម្មវិធីនេះបង្ហាញពីតួនាទីរបស់មីក្រូហិរញ្ញវត្ថុ ក្នុងការគាំទ្រសិទ្ធិទទួលបានផ្ទះសម្បែងដែលមានគុណភាព សម្រាប់ក្រុមដែលមានចំណូលទាប និងក្រុមដែលត្រូវបានគេមើលរំលង ដែលពួកគេមិនអាចទទួលបាន ឬអាចទទួលបានតិចតួចនូវហិរញ្ញវត្ថុសម្រាប់ទិញផ្ទះ។ កម្មវិធីឆ្នាំនេះ គឺមានការប្រកួតប្រជែងខ្លាំង ដែលមានស្ថាប័នដាក់ពាក្យចំនួន ៣៧ មកពី ២៣ប្រទេស ។ តាមរយៈការទទួលស្គាល់នេះ បានជម្រុញទឹកចិត្តឲ្យ ហ្វីស ហ្វាយនែន បន្តការរីកចម្រើន ការបណ្តុះបណ្តាល និងវិជ្ជាជីវៈរបស់ខ្លួន ដើម្បីគាំទ្រអតិថិជនចាស់ ក៏ដូចជាទទួលបានអតិថិជនទិញផ្ទះថ្មីបន្ថែមទៀត រួមទាំងអ្នកដែលត្រូវការជួសជុលផ្ទះរបស់ពួកគេ ក្នុងឆ្នាំ២០១៨ ផងដែរ។

**Lee-Anne Pitcaithly**
ប្រធានក្រុមប្រឹក្សាភិបាល

**អ្នកស្រី ជុន សុថានី**
អគ្គនាយិកា



# អំពី ហ្វឺស ហ្វាយនែន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វឺស ហ្វាយនែន ភីអែលស៊ី គឺជាក្រុមហ៊ុនដែលបណ្តាក់ទុនរួមគ្នារវាង ក្រុមហ៊ុន ហ្វឺស ហូម ភីអែលស៊ី ដែលមានទីតាំងក្នុងប្រទេសកម្ពុជា Phillip Capital ដែលមានទីតាំងក្នុងប្រទេសសិង្ហបុរី Insitor Fund ដែលមានទីតាំងក្នុងប្រទេសលុចសំបួរ មូលនិធិអភិវឌ្ឍន៍កម្ពុជា ឡាវ ( Cambodia-Laos Development Fund ) និង Norfund ដែលមានទីតាំងក្នុងប្រទេសន័រវេស។ ហ្វឺស ហ្វាយនែន បានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ ហើយបានក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុឯកទេស ក្នុងការផ្តល់ឥណទានផ្ទះសម្បែងមុនគេក្នុងប្រទេសកម្ពុជា។ ហ្វឺស ហ្វាយនែន ផ្តោតយ៉ាងខ្លាំងទៅលើការផ្តល់ប្រាក់កម្ចីទិញផ្ទះ និងសាងសង់ផ្ទះរយៈពេលវែង ក៏ដូចជាកម្ចីអចលទ្រព្យធានារយៈពេលមធ្យមទៅដល់គ្រួសារដែលមានចំណូលទាប និងមធ្យម ដែលជាទូទៅពុំមានលទ្ធភាពប្រើប្រាស់សេវារបស់គ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការនានា។

ក្រុមហ៊ុន ហ្វឺស ហូម ភីអែលស៊ី ដែលជាក្រុមហ៊ុនស្ថាបនិក ហ្វឺស ហ្វាយនែន បានធ្វើការសាកល្បង និងបានធ្វើឲ្យកាន់តែប្រសើរឡើងនូវគំនិតផ្តួចផ្តើមដំបូង ក្នុងការការផ្តល់ឥណទានផ្ទះសម្បែង ព្រមទាំងបានធ្វើការសិក្សាជាច្រើនទៅលើតម្រូវការទីផ្សារសម្រាប់ផលិតផលនេះ។ ទាំងនេះគឺជាមូលដ្ឋានគ្រឹះដែលនាំឲ្យ ហ្វឺស ហ្វាយនែន រីកចម្រើនទៅមុខយ៉ាងឆាប់រហ័ស។

## អតិថិជនគោលដៅ

អតិថិជនគោលដៅរបស់យើង គឺជាប្រជាជនកម្ពុជាដែលមានចំណូលទាប និងមធ្យម ហើយមានឆន្ទៈចង់វិនិយោគទៅលើផ្ទះទីមួយរបស់គាត់។ ហ្វឺស ហ្វាយនែន មានសាខាក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប បាត់ដំបង កំពង់ចាម នឹងបន្ទាយមានជ័យ និងខេត្តកំពត។ សាខាទាំងនេះ ក៏បម្រើសេវាទៅដល់ ខេត្តកណ្តាល កំពង់ស្ពឺ ប៉ៃលិន ឧត្តរមានជ័យ និង ខេត្តត្បូងឃ្មុំផងដែរ ។

## ចក្ខុវិស័យរបស់យើង

ជួយឲ្យក្រុមគ្រួសារនៅក្នុងប្រទេសកម្ពុជា បានរស់នៅក្នុងសេចក្តីថ្លៃថ្នូរ សុវត្ថិភាព សុភមង្គល និងមានស្ថេរភាព តាមរយៈការផ្តល់លទ្ធភាពឲ្យពួកគាត់មានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ដោយមិនប្រកាន់ឋានៈ និងវណ្ណៈក្នុងសង្គមឡើយ

## បេសកកម្មរបស់យើង

ដើម្បីបង្កើតស្ថេរភាពសេដ្ឋកិច្ចនៃគ្រួសារកម្ពុជា ដែលមានចំណូលទាបតាមរយៈការផ្តល់លទ្ធភាព និងឱកាសក្លាយជាម្ចាស់កម្មសិទ្ធិនៃផ្ទះសម្បែង





## គុណតម្លៃរបស់យើង IRISE

**សុចរិតភាព**
ដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់យើង យើងប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ និងមានតម្លាភាពគ្រប់សកម្មភាពការងាររបស់យើង ។

**ការឆ្លើយតប**
យើងតែងនៅកៀកស្និទ្ធជាមួយអតិថិជនគ្រប់គ្រាន់ល្មម ដែលអាចឲ្យយើងផ្តល់ការយកចិត្តទុកដាក់ និងឆ្លើយតបតម្រូវការរបស់ពួកគាត់ទាន់ពេលវេលា ។ យើងក៏មានទំនួលខុសត្រូវគ្រប់ទង្វើរបស់យើង និងបើកចិត្តទូលាយក្នុងការទទួលយកការរិះគន់ដើម្បីស្ថាបនាផងដែរ ។

**ភាពច្នៃប្រឌិតខ្ពស់**
យើងមានគំនិតច្នៃប្រឌិតខ្ពស់ ក្នុងការស្វែងរកដំណោះស្រាយដែលមានប្រសិទ្ធិភាពដើម្បីបម្រើអតិថិជនរបស់យើងឲ្យកាន់តែប្រសើរជាងមុន ។

**ភាពស្មើគ្នា**
យើងមានមោទនភាពចំពោះការគោរព ការមានជំនាញវិជ្ជាជីវៈច្បាស់លាស់ និងការបម្រើដល់អតិថិជនដោយស្មើភាព។

**ឧត្តមភាព**
ការងាររបស់យើងគឺធ្វើឡើងដោយអស់ពីកម្លាំងកាយចិត្ត។

# សមិទ្ធផលរបស់យើង

ឆ្នាំ២០១៧ គឺជាឆ្នាំទី៨ នៃការប្តេជ្ញាចិត្តរបស់យើង ក្នុងការគាំទ្រការបង្កើត និងធ្វើឱ្យមានស្ថេរភាពទ្រព្យសម្បត្តិសម្រាប់គ្រួសារកម្ពុជាដែលមានចំណូលទាប និងមធ្យម។ មុនចុងឆ្នាំ២០១៧ ផលបត្រឥណទានរបស់យើងមាន ២០,១ លានដុល្លារ កើនឡើង ២% ធៀបនឹងឆ្នាំ២០១៦ ។ ប្រជាពលរដ្ឋដែលមានចំណូលតិចជាង ៦ដុល្លារ ក្នុងមួយថ្ងៃ ទទួលបាន ១៥% នៃកម្ចីរបស់យើង ខណៈដែល ៥០% នៃកម្ចីត្រូវបានទទួលដោយពលរដ្ឋ ដែលមានប្រាក់ចំណូលតិចជាង១២ដុល្លារក្នុងមួយថ្ងៃ។យោងតាមសេចក្តីប្រកាសពីធនាគារជាតិនៃកម្ពុជា ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនកាលពីខែធ្នូ ឆ្នាំ២០១៧ យើងបានបង្កើនការគ្រប់គ្រងហានិភ័យរបស់យើងលើកម្ចីដែលមិនដំណើរការដែលប៉ះពាល់ជាអវិជ្ជមានលើប្រាក់ចំណេញប្រចាំឆ្នាំចំនួន ៤៤,000ដុល្លារ។ កម្ចីដែលមិនដំណើរការមានផលប៉ះពាល់តិចតួចលើប្រាក់ចំណេញ ពីព្រោះ ហ្វីស ហ្វាយនែន មិនដូចគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុភាគច្រើននោះទេ ដោយហេតុថាយើងយកអចលនទ្រព្យពិតធ្វើជារបស់បញ្ចាំ។

ក្នុងឆ្នាំ២០១៧ យើងបានផ្តោតលើការកសាងសមត្ថភាពដល់បុគ្គលិក និងការគ្រប់គ្រងកម្ចីដែលមិនដំណើរការ។ ថ្វីត្បិតកំណើនផលបត្រឥណទានបានកើនឡើង ២% ប៉ុន្តែយើងមិនទទួលបានប្រាក់ចំណេញគួជាទីគាប់ចិត្តនោះទេ ដោយសារប្រាក់មិនបានបញ្ចេញប្រើ និងតម្លៃប្រតិបត្តិការមានចំនួនខ្ពស់(កំណើននៅទ្រឹង)។ តែទោះបីជាប្រាក់ចំណេញទាប យើងបានមើលឃើញសញ្ញាវិជ្ជមានក្នុងឆមាសទី២ ដែលយើងបានបញ្ចេញប្រាក់កម្ចីជាង ៩00,000 ដុល្លារ ក្នុងមួយខែៗ បើធៀបនឹងឆមាសទី១ គឺមានតែជាង ៣00,000ដុល្លារ ក្នុងមួយខែ ហើយកម្ចីដែលមិនដំណើរការថយចុះមកត្រឹម ៣.៥១% បើធៀបកាលពីឆ្នាំមុនមានដល់ ៤.៥២% ។

កម្ចីសកម្មរបស់យើងបានកើនឡើង ២% ដែលស្មើនឹង ២,២២០ ហើយទំហំផលបត្រឥណទានរបស់យើងបានកើនដល់ ២០,០៥៤.០៧៣ ដុល្លារ ។ ហើយអតិថិជនដែលជាស្ត្រីមាន ៥៨% នៃផលបត្រឥណទានរបស់យើងក្នុងឆ្នាំ២០១៧ ។ អតិថិជនដែលជាអ្នកប្រកបរបរខ្លួនឯង ម្ចាស់អាជីវកម្មខ្នាតតូច មានចំនួន ៥២% ។ ភាគច្រើននៃអតិថិជនទាំងនេះមិនអាចទទួលបានសេវាហិរញ្ញវត្ថុផ្លូវការនោះទេ ដោយសារស្ថានភាពការងាររបស់ពួកគេ។

យើងបានផ្តល់សេវាកម្មដល់គ្រួសារកម្ពុជាក្នុងទីក្រុង និងខេត្តភាគច្រើនដែលមានសាខារបស់យើងដូចជា ទីក្រុងភ្នំពេញ ខេត្តសៀមរាប បន្ទាយមានជ័យ បាត់ដំបង ភ្នំពេញ កំពង់ចាម និងកំពត។ សាខាទាំងនេះក៏ផ្តល់សេវាកម្មដល់ខេត្តកណ្តាល កំពង់ស្ពឺ តាកែវ ប៉ៃលិន ឧត្តមានជ័យ កំពង់ធំ និងត្បូងឃ្មុំ។ នៅ ហ្វីស ហ្វាយនែន យើងបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីទៅដល់គោលដៅរបស់យើង ក្នុងការផ្តល់កម្ចីលំនៅដ្ឋានទៅដល់គ្រួសារកម្ពុជាដែលមានចំណូលទាប និងមធ្យម។

## ចំនួនអតិថិជនតាមប្រភពចំណូល

48% អ្នកធ្វើការ

អ្នករកស៊ី ធៀបនឹង អ្នកធ្វើការ

52% អ្នករកស៊ី

## ចំនួនអតិថិជនតាមចំណូលប្រចាំថ្ងៃ

15% ដល់ប្រជាជនដែលមានចំណូលទាបជាង ៦ដុល្លា/១ថ្ងៃ

50% ដល់ប្រជាជនដែលមានចំណូលទាបជាង ១២ដុល្លា/១ថ្ងៃ

## ចំនួនអតិថិជនតាមភេទ

58% ស្ត្រី

42% បុរស

## ចំនួនអតិថិជនសរុប

ច្រើនជាង

1,595

គ្រួសារដែលមាន ចំណូលទាប និងមធ្យម

# អំពីផលិតផល

បើគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ យើងមានកម្ចីសកម្មចំនួន ២,២២៤ នៅលើទីផ្សារ ជាមួយផលប័ត្រឥណទានចំនួន ២០ លានដុល្លារ ។ បច្ចុប្បន្ន យើងមានផលិតផល ៤ ប្រភេទដូចខាងក្រោម៖

## កម្ចីទិញផ្ទះ

កម្ចីទិញផ្ទះរបស់ ហ្វីស ហ្វាយនែន បានអនុញ្ញាតិឲ្យក្រុមគ្រួសារដែលមានចំណូលទាប និងមធ្យម មានផ្ទះទីមួយជាកម្មសិទ្ធិផ្ទាល់ខ្លួន ។ យើងផ្តល់លទ្ធភាពឲ្យអតិថិជនខ្ចីបានរហូតដល់ ៨៥% នៃតម្លៃផ្ទះ ក្នុងរយៈពេល២០ឆ្នាំ ជាមួយអត្រាការប្រាក់ដែលមានលក្ខណៈប្រកួតប្រជែង ហើយអនុញ្ញាតិឲ្យអតិថិជនរួមគ្នាខ្ចីបានដល់ទៅ ៣នាក់។

កម្ចីទិញផ្ទះសរុបមានចំនួន ៥១៧ ។ កម្ចីនេះមានចំណែកប្រមាណ ៣៥.៥% នៃផលប័ត្រឥណទានសរុប ។

**35.5%** នៃផលប័ត្រឥណទានសរុប

**517** ចំនួនប្រាក់កម្ចីសកម្ម

## កម្ចីទិញដីលំនៅដ្ឋាន

កម្ចីទិញដីលំនៅដ្ឋាន ជាផលិតផលសំខាន់មួយ ដែលមានរយៈពេលវែងសម្រាប់អ្នកមានបំណងទិញដីទុកសាងសង់លំនៅដ្ឋាន

ជាមួយ រយៈពេលវែងរហូតដល់ ២០ឆ្នាំ និងអាចខ្ចីបានរហូតដល់ ៦៥%នៃតម្លៃសរុប ផលិតផលនេះមានចំនួនសរុប ១២៧ ដែលស្មើនឹង ៥.៦% នៃផលបត្រឥណទានសរុប ។

**5.6%** នៃផលប័ត្រឥណទានសរុប

**127** ចំនួនប្រាក់កម្ចីសកម្ម

## កម្ចីសាងសង់ ជួសជុលផ្ទះ

កម្ចីសាងសង់ផ្ទះ គឺជាផលិតផលសំខាន់មួយទៀតរបស់យើង ដែលអាចផ្តល់ដំណោះស្រាយផ្នែកហិរញ្ញវត្ថុរយៈពេលវែងសម្រាប់អ្នកមានបំណងសាងសង់ផ្ទះថ្មីលើផ្ទៃដីដែលមានស្រាប់ ឬជួសជុលផ្ទះដែលមានស្រាប់។

ផលិតផលនេះមានលក្ខណៈពិសេស ដោយការបង់សងមានរយៈកាលដល់ទៅ ២០ឆ្នាំ និងមានទំហំកម្ចីដល់ទៅ ១00% នៃតម្លៃសាងសង់សរុប ។ ផលិតផលនេះមានចំនួន ៩៤៣ ដែលស្មើនឹង ៣៧% នៃផលប័ត្រឥណទានសរុប។

**37%** នៃផលប័ត្រឥណទានសរុប

**943** ចំនួនប្រាក់កម្ចីសកម្ម

## កម្ចីអចលនទ្រព្យធានា

កម្ចីអចលនទ្រព្យធានា ត្រូវបានបន្ថែមលើផលិតផលផ្ទះសម្បែងដែលមានស្រាប់ ដើម្បីជួយអតិថិជនរបស់ ហ្វីស ហ្វាយនែន ក្នុងការទិញសម្ភារៈប្រើប្រាស់ ក៏ដូចជាបង្កើត ឬពង្រីកអាជីវកម្មរបស់ពួកគេ ។ ប្រាក់កម្ចីនេះអនុញ្ញាតិឲ្យអតិថិជនរបស់យើង អាចប្រើប្រាស់អចលនទ្រព្យរបស់ពួកគាត់ ក្នុងការចាប់យកឱកាសផ្នែកហិរញ្ញវត្ថុផ្សេងៗទៀត។

រយៈពេលបង់សងរបស់កម្ចីនេះគឺរហូតដល់ ១០ ឆ្នាំ ដែលគិតមកទល់បច្ចុប្បន្ន កម្ចីនេះមានចំនួន ៦១២ ស្មើនឹង ២១.៦% នៃផលប័ត្រឥណទានសរុបរបស់យើង ។

**21.6%** នៃផលប័ត្រឥណទានសរុប

**612** ចំនួនប្រាក់កម្ចីសកម្ម



# តំបន់ប្រតិបត្តិការ



# ដៃគូវិនិយោគ



## ភាគទុនិក

First Finance
www.firstfinance.biz

CLDF Cambodia-Laos Development Fund
www.emergingmarkets.asia

Norfund
www.norfund.no

PhillipCapital Your Partner In Finance
www.phillip.com.sg

INSITOR FUND
www.insitormanagement.com

## អ្នកវិនិយោគប្រាក់កម្ចី

FINNFUND
www.finnfund.fi

BlueOrchard
www.blueorchard.com

OIKO CREDIT
www.oikocredit.coop

Triple Jump
www.triplejump.eu

symbiotics
www.symbioticsgroup.com

PhillipBank Your Partner In Finance
www.phillipbank.com.kh

incofin
www.incofin.com

Norfund
www.norfund.no

bio
www.bio-invest.be



# រចនាសម្ព័ន្ធ ហ្វីស ហ្វាយនែន





# ការអភិវឌ្ឍជាប្រចាំ

## ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍

ក្នុងកិច្ចខិតខំប្រឹងប្រែងបន្តធ្វើឱ្យប្រសើរឡើងចំពោះស្ថាប័ន ក៏ដូចជាសេវាកម្មដែល ហ្វីស ហ្វាយនែន ផ្តល់ដល់អតិថិជន នាយកដ្ឋានបណ្តុះបណ្តាល និងអភិវឌ្ឍន៍ត្រូវបានបង្កើតឡើងនៅចុងឆ្នាំ២០១៦ ។ នាយកដ្ឋាននេះត្រូវបានបង្កើតឡើងក្នុងគោលបំណងកសាងសមត្ថភាពរបស់បុគ្គលិកឱ្យពេញលេញដើម្បីគាំទ្រការរីកចម្រើននៃអាជីវកម្ម។ ក្នុងឆ្នាំ២០១៧ នាយកដ្ឋានបណ្តុះបណ្តាល និងអភិវឌ្ឍន៍បានផ្តល់ការបណ្តុះបណ្តាល ដល់បុគ្គលិកទាំងអស់របស់ ហ្វីស ហ្វាយនែន (បុគ្គលិកថ្មី ៦៨នាក់ និងបុគ្គលិកចាស់ ១៣៩នាក់) មកពីគ្រប់សាខា។ ការផ្តល់វគ្គបណ្តុះបណ្តាលលើប្រព័ន្ធថ្មីត្រូវបានរៀបចំនៅចុងឆ្នាំ។ បន្ថែមលើការបណ្តុះបណ្តាលខាងក្នុងស្ថាប័ន បុគ្គលិកត្រូវបានផ្តល់ឱកាសដើម្បីអភិវឌ្ឍទាំងជំនាញតាមតួនាទី និងជំនាញទន់ ដើម្បីធ្វើឱ្យប្រសើរឡើង នូវជំនាញរបស់ពួកគេក្នុងតួនាទីបច្ចុប្បន្ន និងការអភិវឌ្ឍជំនាញនាពេលអនាគត។ បុគ្គលិកចំនួន ១៥០នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលផ្សេងៗ ទាំងក្នុងប្រទេសកម្ពុជា និងបរទេស ដែលក្នុងនោះបុគ្គលិក ២នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលមួយ ក្នុងប្រទេសសិង្ហបុរី។ បុគ្គលិកគាំទ្របានទទួលវគ្គបណ្តុះបណ្តាលទាក់ទងសេវាអតិថិជន ធនធានមនុស្ស ភាពជាអ្នកដឹកនាំ ពន្ធដា និងភាសាអង់គ្លេស។





## ប្រតិបត្តិការអាជីវកម្មដោយស្វ័យប្រវត្តិ

ប្រព័ន្ធគ្រប់គ្រងឥណទាន និងហិរញ្ញវត្ថុ (core banking) ដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់នូវសេវាកម្មដែលល្អ និងធ្វើឲ្យប្រសើរឡើងនូវបទពិសោធន៍ដែលអតិថិជនទទួលបាន។ ក្នុងឆ្នាំ២០១៧ ហ្វីស ហ្វាយនែន បានចាប់ផ្តើមអនុវត្តប្រព័ន្ធ MorakotVB ដែលជាកម្មវិធី core banking ។ Morakot VB គឺជាប្រព័ន្ធប្រតិបត្តិការដែលងាយស្រួលប្រើ និងមានតម្លៃសមរម្យ សម្រាប់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។ កម្មវិធីនេះដំណើរការនៅលើអ៊ីនធឺណិត ដោយយើងពុំចាំបាច់ត្រូវការរចនាសម្ព័ន្ធកម្មវិធីដែលមានតម្លៃថ្លៃនោះទេ។ លើសពីនេះទៀតវាបានផ្តល់នូវមុខងារពិសេសជាច្រើនរាប់ចាប់ពីផ្នែកគណនេយ្យរបាយការណ៍ស្តីពីការគ្រប់គ្រងអតិថិជន រួមទាំងសំណើកម្ចី ការធានាការគ្រប់គ្រងកិច្ចសន្យាកម្ចី តួនាទីអ្នកផ្តល់ព័ត៌មាន និងការគ្រប់គ្រងកម្ចីដែលមានបញ្ហា។ កម្មវិធីនេះមានភ្ជាប់ជាមួយប្រព័ន្ធគណនេយ្យដែលដើរដោយស្វ័យប្រវត្តិ ដែលមានតារាងអាចកែសម្រួលបានលើគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ ដែលមានន័យថាប្រព័ន្ធនេះនឹងកត់ត្រាដំណើរការប្រាក់កម្ចីដែលទាក់ទងដោយស្វ័យប្រវត្តិ ដែលជួយកាត់បន្ថយបញ្ហាដែលកើតមាន និងបន្ទុកការងារ។ កម្មវិធីនេះគាំទ្រដល់កម្មវិធីរបស់ការិយាល័យឥណទាន (Credit Bureau) ដែលអាចឱ្យអ្នកប្រើប្រាស់ត្រួតពិនិត្យមើលប្រវត្តិរបស់ពួកគេដោយផ្ទាល់លើប្រព័ន្ធ។

## ការពង្រីកប្រតិបត្តិការ

ក្នុងឆ្នាំ២០១៧ ដើម្បីគាំទ្រការរីកចម្រើនរបស់ខ្លួន ហ្វីស ហ្វាយនែន បានសម្ពោធសាខាថ្មីចំនួនបួនបន្ថែមទៀត សាខាថ្មីចំនួនពីរស្ថិតក្នុងទីក្រុងភ្នំពេញ ដែលទីមួយស្ថិតនៅជិតរង្វង់មូលកាំកូ ក្នុងខណ្ឌទួលគោក និងទីពីរស្ថិតក្នុងខណ្ឌពោធិ៍សែនជ័យ តាមបណ្តោយផ្លូវជាតិលេខ៣ (ភ្នំពេញទៅកំពត) ប្រហែល ៣គីឡូម៉ែត្រ ពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ សាខាចំនួនពីរទៀតត្រូវបានបើកនៅតាមខេត្ត អាស្រ័យដោយមើលឃើញការកើនឡើងនៃកំនើនសេដ្ឋកិច្ច និងតម្រូវការផ្ទះថ្មី ឬការជួសជុលផ្ទះនៅក្នុងតំបន់ទាំងនេះ។ សាខាមួយបានបើកក្នុងខេត្តកំពត និងមួយទៀតក្នុងខេត្តបាត់ដំបង ក្នុងស្រុកភ្នំព្រឹក ដែលមានព្រំប្រទល់ជាប់ប្រទេសថៃ។ សាខាបើកថ្មីទាំងបួននេះ ត្រូវបានរៀបចំឡើងតាមអត្តសញ្ញាណ ហ្វីស ហ្វាយនែន ដោយបំពាក់សំភារគ្រប់គ្រាន់ ដែលផ្តល់នូវផាសុខភាពសម្រាប់អតិថិជន ឬភ្ញៀវសាកសួរព័ត៌មាន ព្រមជាមួយកន្លែងធ្វើការប្រកបដោយវិជ្ជាជីវៈសម្រាប់បុគ្គលិករបស់យើង។ យើងក៏បានជ្រើសរើសបុគ្គលិក ដែលមានជំនាញ និងរួសរាយរាក់ទាក់ ហើយពួកគេតែងតែត្រៀមខ្លួនជាស្រេច ដើម្បីផ្តល់សេវាដ៏ល្អដល់អតិថិជនរបស់យើង ក្នុងតំបន់ថ្មីៗទាំងនេះ។










**“ប្រាក់កម្ចីរបស់ ហ្វីស ហ្វាយនែន ផ្តល់ឱកាសឲ្យខ្ញុំអាចរស់នៅក្នុងផ្ទះដ៏ពិតប្រាកដម្តងទៀត”**

កញ្ញា ភិន ណាលីន រស់នៅជាមួយម្តាយដែលជាស្ត្រីមេម៉ាយ ក្នុងផ្ទះរបស់នាងស្ថិតនៅតាមបណ្តោយផ្លូវជាតិក្នុងខេត្តកំពង់ចាម។ ផែនការរបស់រាជរដ្ឋាភិបាលក្នុងការធ្វើឱ្យប្រសើរឡើងហេដ្ឋារចនាសម្ព័ន្ធនៅទូទាំងប្រទេស ដែលកាត់បន្ថយក្នុងការកាត់បន្ថយការកកស្ទះចរាចរណ៍។ តែសម្រាប់ណាលីន ការពង្រីកផ្លូវជាតិនេះបានកាត់ផ្ទះរបស់គាត់នៅសល់បណ្តោយត្រឹមតែប្រវែង ២ម៉ែត្រ ប៉ុណ្ណោះ ។

នេះជាស្ថានភាពដ៏លំបាក ហើយដោយគ្មានជម្រើសផ្សេង នាង និងម្តាយបានសម្រេចចិត្តទៅរស់នៅក្នុងតូបដ៏តូចមួយក្នុងផ្សារជាកន្លែងដែលនាងលក់សំលៀកបំពាក់ជារៀងរាល់ថ្ងៃ។ ពួកគេបានរស់នៅទីនោះអស់រយៈពេល ៣ឆ្នាំ ប៉ុន្តែវាមិនមែនជាដំណោះស្រាយដែលល្អបំផុតនោះទេ ខណៈពេលដែលនាងខិតខំប្រឹងលក់ដូរ ហើយដែលត្រូវរក្សារបស់របររស់នៅទាំងអស់នៅក្នុងតូបដ៏តូចនេះ។

ពេលដែល ភិន ណាលិន បានឃើញបណ្ណព័ត៌មានរបស់ ហ្វីស ហ្វាយនែន ដែលពន្យល់ពីការទទួលបានកម្ចីសម្រាប់ទិញផ្ទះជាមួយអត្រាការប្រាក់សមរម្យ នាងបានសម្រេចចិត្តទាក់ទង ហ្វីស ហ្វាយនែន ដើម្បីឈ្វេងយល់បន្ថែម។ ក្រោយពីទទួលបានការប្រឹក្សា នាងបានសម្រេចចិត្តស្នើកម្ចីទិញដីដើម្បីសង់ផ្ទះថ្មី។ ជាមួយនឹងប្រាក់ចំណូលប្រចាំខែ ៥៩៥ ដុល្លារពីការលក់ដូររបស់នាង ធ្វើឱ្យនាងអាចទទួលបានកម្ចីចំនួន ៥,០០០ ដុល្លារ ក្នុងខែមករា ឆ្នាំ២០១៧ ដើម្បីទិញដីក្នុងស្រុកចម្ការលើ ខេត្តកំពង់ចាម។ ក្រោយមកនាងបានស្នើប្រាក់កម្ចីសម្រាប់សង់ផ្ទះចំនួន ១២,៥០០ ដុល្លារ បន្ថែមទៀតក្នុងខែសីហា ឆ្នាំ២០១៧ ដដែល ដើម្បីសង់ផ្ទះប្រវែង ៤,៣×១៥ ម៉ែត្រ ដែលមកដល់ឥឡូវបានសាងសង់រួច ៨០% ហើយ។

កម្ចីរបស់ ភិន ណាលិន គឺសម្រាប់រយៈពេល ១៨០ខែ ហើយនាងសប្បាយរីករាយណាស់ ដែល ហ្វីស ហ្វាយនែន អាចផ្តល់ប្រាក់កម្ចីសម្រាប់រយៈពេលវែងដូចនេះ ដែលអាចឱ្យនាងមានទំនុកចិត្តក្នុងការបង់សង ហើយប្រាក់កម្ចីនេះគឺសម្រាប់ការសង់ផ្ទះឱ្យបានរួចរាល់។ នាង និងម្តាយទន្ទឹងចាំយ៉ាងរីករាយនៅពេលដែលផ្ទះត្រូវបានសង់រួច ហើយនាងបានថ្លែងអំណរគុណដល់ហ្វីស ហ្វាយនែន ដោយបាននិយាយថា ៖ “ប្រាក់កម្ចី ហ្វីស ហ្វាយនែន អាចឱ្យខ្ញុំមានឱកាសរស់នៅក្នុងផ្ទះដ៏ពិតប្រាកដម្តងទៀត “.

# ព្រឹត្តិការណ៍ប្រចាំឆ្នាំ



## ការផ្សព្វផ្សាយនៅទីសាធារណៈ

*ថ្ងៃទី៦ ខែមករា ឆ្នាំ២០១៨ @ សៀមរាប*

បុគ្គលិកជាង ១០០នាក់ មកពីសាខាផ្សេងៗ រួមទាំងគណៈគ្រប់គ្រង និងអគ្គនាយិកា បានធ្វើសកម្មភាពផ្សព្វផ្សាយពី ហ្វីស ហ្វាយនែន នៅផ្សារធំៗ ចំនួនបួនក្នុងក្រុងសៀមរាប ។ យុទ្ធនាការនេះទទួលបានការចាប់អារម្មណ៍យ៉ាងច្រើនពីម្ចាស់តូបលក់ឥវ៉ាន់ អ្នកទិញឥវ៉ាន់ និងការយល់ដឹងពីសេវាកម្ម និងផលិតផលរបស់ ហ្វីស ហ្វាយនែន ។







## សិក្ខាសាលាប្រចាំឆ្នាំ

*ថ្ងៃទី៦ ខែមករា ឆ្នាំ២០១៨ @ សៀមរាប*

នៅហ្វីស ហ្វាយនែន យើងឆ្លុះបញ្ចាំងពីការងាររបស់យើងជាទៀងទាត់ ដែលសិក្ខាសាលាប្រចាំឆ្នាំរបស់យើងឆ្នាំនេះដាក់ឈ្មោះថា “បញ្ហាប្រឈមធ្វើឱ្យយើងកាន់តែរឹងមាំ” ។ ក្នុងអំឡុងពេលសិក្ខាសាលា អ្នកចូលរួមទាំងអស់ធ្វើការឆ្លុះបញ្ចាំងលើបញ្ហាប្រឈម ដែលបានធ្វើឱ្យពួកគេមិនអាចបំពេញការងារបានល្អ និងវិធីសាស្ត្រដើម្បីយកឈ្នះ និងធ្វើឱ្យប្រសើរឡើងការងាររបស់ពួកគេ ។
ជាផ្នែកមួយនៃកម្មវិធី អគ្គនាយិការបស់ហ្វីស ហ្វាយនែន គឺលោកស្រី ជុន សុថានី បានផ្តល់គ្រឿងទទួលស្គាល់ដល់បុគ្គលិកចំនួន ១២នាក់ សម្រាប់ការឱ្យតម្លៃ និងថ្លែងអំណរគុណចំពោះការប្រឹងប្រែងធ្វើការងាររបស់ពួកគេជាមួយហ្វីស ហ្វាយនែន បានយ៉ាងតិច ៥ឆ្នាំ និងការបន្តការងាររបស់ពួកគេទៅមុខទៀត ។





## ការបរិច្ចាគឈាម

*ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៧ @ ភ្នំពេញ*

ការបរិច្ចាគឈាមដោយស្ម័គ្រចិត្តជាផ្នែកមួយនៃកម្មវិធីសប្បុរសធម៌សម្រាប់សង្គមរបស់ ហ្វីស ហ្វាយនែន ។ បុគ្គលិករបស់យើងមកពីបីសាខាក្នុងរាជធានីភ្នំពេញ បានបរិច្ចាគឈាមរបស់ពួកគេនៅមជ្ឈមណ្ឌលជាតិផ្តល់ឈាម ក្នុងខែធ្នូ ឆ្នាំ២០១៧ ។ នេះជាសកម្មភាពដ៏ចាំបាច់បំផុត ហើយយើងមានមោទនភាពចំពោះការបរិច្ចាគរបស់បុគ្គលិករបស់យើង ។







## កម្មវិធីទស្សនកិច្ចរបស់ដៃគូវិនិយោគ

*ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ @ សៀមរាប*

ហ្វីស ហ្វាយនែន ប្តេជ្ញាចិត្តកសាងទំនាក់ទំនងល្អជាមួយដៃគូវិនិយោគរបស់ខ្លួន ដែលយើងបានរៀបចំកម្មវិធីទស្សនកិច្ចរបស់ពួកគេក្នុងទីក្រុងភ្នំពេញក្នុងឆ្នាំ២០១៦ ។ បន្ទាប់ពីរៀបចំកម្មវិធីលើកទីមួយបានជោគជ័យ យើងបានរៀបចំកម្មវិធីនេះជាលើកទីពីរក្នុងខែសីហា ឆ្នាំ២០១៧ ក្នុងខេត្តសៀមរាប ។ គោលបំណងនៃកម្មវិធីនេះ គឺដើម្បីផ្តល់ឱកាសដល់ដៃគូវិនិយោគរបស់យើងអាចឈ្វេងយល់ពីលទ្ធផលដែលកម្ចីផ្នែកលំនៅដ្ឋានខ្នាតតូចរបស់យើងផ្តល់ផលប៉ះពាល់ជាវិជ្ជមាន ទៅដល់គ្រួសារកម្ពុជាដែលមានចំណូលទាប និងមធ្យមនៅកម្ពុជា ។

## កម្មវិធីណែនាំសម្រាប់អតិថិជន

*ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧ @ ភ្នំពេញ*

ហ្វីស ហ្វាយនែន ធានាថា អតិថិជនរបស់ខ្លួនពេញចិត្តនឹងរួមដំណើរជាមួយគ្នា ដូច្នេះហើយយើងបានបង្កើតកម្មវិធីមួយដើម្បីផ្តល់រង្វាន់ដល់អតិថិជន ។ កម្មវិធីនេះធ្វើឡើងតាមរយៈការណែនាំតគ្នា ។ នៅពេលដែលអតិថិជនណែនាំសេវារបស់យើងដល់មិត្តភក្តិ ឬសាច់ញាតិ នោះឈ្មោះរបស់ពួកគេអាចចូលរួមផ្សងសំណាង ។ ក្នុងខែធ្នូ ឆ្នាំ២០១៧ យើងបានផ្តល់រង្វាន់ទូរសព្ទដៃម៉ាក Iphone 7 មួយគ្រឿង ដល់អ្នកឈ្នះរង្វាន់តាមរយៈការចាប់ឆ្នោត ហើយអតិថិជនដែលត្រូវបានគេណែនាំក្នុងកម្មវិធីនេះ ទទួលបានការបញ្ចុះតម្លៃ ៥០% លើសេវារដ្ឋបាល ។ នេះជាផ្នែកមួយនៃយុទ្ធសាស្ត្ររក្សាអតិថិជនរបស់យើង ។







## អនុស្សារណៈយោគយល់គ្នាជាមួយ CAMLIFE ៖ សុវត្ថិភាពហិរញ្ញវត្ថុសម្រាប់អតិថិជនទាំងអស់

*ថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៧ ភ្នំពេញ*

ហ្វឺស ហ្វាយនែន និងក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតកម្ពុជា "Camlife" បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា ក្នុងខែធ្នូ ឆ្នាំ២០១៧ ដើម្បីផ្តល់សុវត្ថិភាពផ្នែកហិរញ្ញវត្ថុសម្រាប់អតិថិជនទាំងអស់ ។ អតិថិជនរបស់ ហ្វឺស ហ្វាយនែន នឹងទទួលបានអត្ថប្រយោជន៍ពីកិច្ចសហការនេះ ដោយទទួលបានតម្លៃពិសេសពី Camlife សម្រាប់ការប្រើប្រាស់សេវាធានារ៉ាប់រងអាយុជីវិតជាពិសេសសម្រាប់ប្រាក់កម្ចីដែលនៅជំពាក់នៅពេលដែលអតិថិជនស្ថិតក្នុងហានិភ័យគ្រោះថ្នាក់ដល់ស្លាប់ ឬពិការភាពទាំងស្រុង ។





## ពិធីសម្ពោធសាខាថ្មីនៅខេត្តកំពត

*ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៧ @ កំពត*

ដោយមើលឃើញពីកំណើនសេដ្ឋកិច្ចដ៏មានសក្តានុពល ក្នុងខេត្តកំពត ហ្វឺស ហ្វាយនែន បានពង្រីកប្រតិបត្តិការរបស់ខ្លួននៅក្នុងខេត្តនេះ ដើម្បីផ្តល់ឱកាសកាន់តែច្រើនដល់គ្រួសារដែលមានចំណូលទាប និងមធ្យមអាចទទួលបានលទ្ធភាពក្នុងការសាងសង់ផ្ទះ ឬក្លាយជាម្ចាស់កម្មសិទ្ធិផ្ទះដំបូងរបស់ពួកគេ។ ក្នុងខែតុលា ឆ្នាំ២០១៧ ហ្វឺស ហ្វាយនែន បានសម្ពោធការិយាល័យសាខាថ្មីរបស់ខ្លួនក្នុងខេត្តកំពត ។ ពិធីសម្ពោធនេះប្រព្រឹត្តទៅក្រោមអធិបតីភាពលោកអភិបាលក្រុងកំពត លៀង រឿន សុធី អភិបាលខណ្ឌ មេភូមិ ដៃគូសហការអ្នកភូមិ អតិថិជន និងគណៈគ្រប់គ្រងពី ហ្វឺស ហ្វាយនែន ។

ក្នុងកម្មវិធីនោះដែរ យើងបានចែកជូនបំពង់ពន្លត់អគ្គីភ័យដល់ប្រជាជនចំនួន ៥០គ្រួសារ ដែលក្នុងមួយគ្រួសារទទួលបាន ១បំពង់ និងជូនដល់សាលាសង្កាត់ចំនួន ៥ ដែលសង្កាត់នីមួយៗទទួលបាន ៤ បំពង់សម្រាប់ប្រើប្រាស់ជាប្រយោជន៍នៅក្នុងសាលាសង្កាត់ ។



## កម្មវិធីផ្សព្វផ្សាយផលិតផលក្នុងខេត្តកំពត

*ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៧ ខេត្តកំពត*

បន្ទាប់ពីសម្ពោធការិយាល័យសាខាថ្មីនៅខេត្តកំពតក្នុងខែតុលា ឆ្នាំ ២០១៧ ក្រុមការងារហ្វឺស ហ្វាយនែន បានធ្វើការផ្សព្វផ្សាយសេវាកម្ម និងផលិតផល ដល់អតិថិជនដែលមានសក្តានុពលក្នុងខេត្តនេះ ។ ខិត្តប័ណ្ណផ្សព្វផ្សាយ និងកាតណែនាំអតិថិជនចំនួនជាង ២០០០ សន្លឹក ត្រូវបានផ្តល់ទៅដល់អតិថិជនគោលដៅ ដោយក្រុមការងារផ្សព្វផ្សាយរបស់យើង ។ សមាជិកក្រុមការងារផ្សព្វផ្សាយត្រូវបានជ្រើសរើសពីសាកលវិទ្យាល័យក្នុងស្រុក ហើយពួកគេទទួលការបណ្តុះបណ្តាលពីក្រុមការងារទីផ្សារ មុនពេលពួកគេចុះទៅជួបសហគមន៍ ។ កម្មវិធីនេះមិនត្រឹមតែសម្រាប់ការផ្សព្វផ្សាយផលិតផលរបស់ហ្វឺស ហ្វាយនែន ប៉ុណ្ណោះទេ ប៉ុន្តែតាមរយៈកម្មវិធីនេះ យើងចង់ផ្តល់ឱ្យយុវជន និងយុវនារីទទួលបានបទពិសោធន៍ការងារដំបូង ដែលជាផ្នែកមួយនៃកម្មវិធីជ្រើសរើសបុគ្គលិករបស់យើង ។





## កម្មវិធីតម្រង់ទិសអាជីពការងារសម្រាប់និស្សិត

*ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៧ @ កំពង់ចាម*

ហ្វឺស ហ្វាយនែន បានផ្តល់ការប្រឹក្សាលើការចាប់យកអាជីពការងារដំបូងដល់និស្សិតប្រមាណ ១០០នាក់ មកពីសាកលវិទ្យាល័យចំនួនពីរ ក្នុងខេត្តកំពង់ចាម កម្មវិធីនេះធ្វើឡើងដើម្បីលើកទឹកចិត្ត និងណែនាំផ្លូវដល់និស្សិតសម្រាប់អនាគតការងាររបស់ពួកគេ និងជាផ្នែកមួយនៃយុទ្ធសាស្ត្រជ្រើសរើសបុគ្គលិករបស់យើង។ ជាវាគ្មិនម្នាក់នៅក្នុងកម្មវិធីនេះ លោកស្រី ជុន សុថានី អគ្គនាយិកា ហ្វឺស ហ្វាយនែន បានចែករំលែកបទពិសោធន៍របស់គាត់ទៅដល់អ្នកចូលរួមអំពីរបៀបត្រៀមខ្លួនសម្រាប់ទីផ្សារការងារបន្ទាប់ពីបញ្ចប់ការសិក្សា ។

## ពិព័រណ៍ការងារថ្នាក់ជាតិ

*ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៧ នៅផ្សារ AEON*

និស្សិត អ្នកទើបបញ្ចប់ការសិក្សា និងអ្នកជំនាញវ័យក្មេងជាច្រើនបានទៅសួរព័ត៌មាននៅស្តង់របស់ ហ្វឺស ហ្វាយនែន ក្នុងកម្មវិធីពិព័រណ៍ការងារថ្នាក់ជាតិដែលរៀបចំនៅផ្សារ Aeon ។ ពួកគេបានជជែកសួរនាំពីឱកាសការងារនៅ ហ្វឺស ហ្វាយនែន ក៏ដូចជាស្វែងយល់ពីទស្សនៈវិស័យរបស់យើង ក្នុងការផ្តល់កម្ចីខ្នាតតូចទាក់ទងនឹងលំនៅដ្ឋានដល់ប្រជាជនកម្ពុជាដែលមានចំណូលទាប និងមធ្យម ។ យុវជន និងយុវនារីជាច្រើនបានសំដែងការចាប់អារម្មណ៍លើ ហ្វឺស ហ្វាយនែន ហើយពួកគេបានបំពេញពាក្យសុំធ្វើការសម្រាប់តំណែងដែលត្រូវការ។ ហ្វឺស ហ្វាយនែន ទទួលស្គាល់ពីសារៈសំខាន់នៃពិព័រណ៍ការងារនេះ ដែលវាជាវេទិកាមួយដើម្បីបង្ហាញឱកាសការងារផ្សេងៗដល់អ្នកជំនាន់ក្រោយដែលជាកម្លាំងការងារកម្ពុជា ។



# របាយការណ៍សវនករឯករាជ្យ

(ដកស្រង់ពីរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៧ និងរបាយការណ៏របស់សវនករឯករាជ្យ)

## មតិយោបល់

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន ភីអិលស៊ី ហៅកាត់ថា (“ក្រុមហ៊ុន”) ដែលរួមមាន តារាងតុល្យការនាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៧ និងរបាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការបរិច្ឆេទបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានសេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ។

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុ បង្ហាញនូវទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៧ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងបទបញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍ណែនាំដោយចេញដោយធនាគារជាតិនៃកម្ពុជា។

## មូលដ្ឋានក្នុងការផ្តល់មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា (”CISAs”)។ ការទទួលខុសត្រូវរបស់យើងខ្ញុំ យោងតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា ត្រូវបានបរិយាយបន្ថែមនៅក្នុងផ្នែកនៃ “ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការហិរញ្ញវត្ថុ” នៃរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំ មានឯករាជ្យភាពពីសាខាធនាគារ ដោយយោងតាមអនុក្រឹត្យទៅលើក្រមសីលធម៌សម្រាប់វិជ្ជាជីវៈរបស់គណនេយ្យករជំនាញ និងសវនករជំនាញដែលចេញផ្សាយដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំ ក៏បានបំពេញនូវទំនួលខុសត្រូវដទៃទៀតដែលតម្រូវដោយក្រមសីលធម៌នេះដែរ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប ដើម្បីផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

## បញ្ហាដទៃទៀត

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ត្រូវបានធ្វើ សវនកម្មដោយសវនករដទៃទៀត ដែលបានបញ្ចេញមតិយោបល់ដែលមិនមានបញ្ហាទៅលើ របាយការណ៍ហិរញ្ញវត្ថុនាថ្ងៃ ទី៣១ ខែមីនា ឆ្នាំ២០១៦។

## ព័ត៌មានផ្សេងៗក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និង របាយការណ៍របស់សវនករ

គណៈគ្រប់គ្រង ជាអ្នកទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរួមមាន របាយការណ៏របស់គណៈគ្រប់គ្រងប្រតិបត្តិប៉ុន្តែមិនរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុ និងរបាយ-ការណ៏របស់សវនករ។

មតិយោបល់របស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ពុំគ្របដណ្តប់លើព័ត៌មានផ្សេងៗនេះទេ ហើយយើងខ្ញុំក៏មិនបង្ហាញសេចក្តីសន្និ-ដ្ឋានធានាក្នុងទម្រង់ណាមួយទៅលើព័ត៌មានផ្សេងៗនេះដែរ។

ទាក់ទិននឹងការធ្វើសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុ ទំនួលខុសត្រូវរបស់យើងខ្ញុំគឺការស្វែងយល់ព័ត៌មានផ្សេងៗនេះ និងធ្វើការពិចារណាថាតើព័ត៌មានផ្សេងៗនេះ មានលក្ខណៈមិនសមស្របជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុឬទេ ឬចំណេះដឹងរបស់យើងខ្ញុំដែលទទួលបាននៅក្នុងការធ្វើសវនកម្មទំនងជាមានកំហុសឆ្គងជាសារវន្តឬទេ។ ប្រសិនបើយើងខ្ញុំ សន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តលើព័ត៌មានផ្សេងៗនេះដោយផ្អែកលើការងារដែលបានអនុវត្ត យើងខ្ញុំតម្រូវឲ្យរាយការណ៍តាមភាពជាក់ស្តែង។ យើងខ្ញុំពុំមានហេតុការណ៍អ្វីត្រូវរាយការណ៍ចំពោះពត៌មានផ្សេងៗនេះទេ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រង ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និងការបង្ហាញទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា ហើយនិងបទប្បញ្ញត្តិ និងគោលការណ៍ណែនាំទាក់ទិនផ្សេងៗ ដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា ហើយនិងទទួលខុសត្រូវផងដែរចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងគិតថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលពុំមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវក្នុងការវាយតម្លៃលើនិរន្តរភាពអាជីវកម្មរបស់ក្រុមហ៊ុន និងធ្វើការលាតត្រដាង (ប្រសិនបើមាននូវបញ្ហាទាំងឡាយណាដែលទាក់ទងនឹង និរន្តរភាពអាជីវកម្ម និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្មនៅក្នុងប្រព័ន្ធគណនេយ្យរបស់ក្រុមហ៊ុន លើកលែងតែក្នុងករណីគណៈគ្រប់គ្រងមានបំណងរំលាយ ឬបញ្ឈប់ប្រតិបត្តិការណ៍ធនាគារ ឬ ក៏គ្មានមធ្យោបាយជាក់លាក់ណាមួយទៀតក្រៅពីនេះ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យមើលលើដំណើរការនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងដែលសមហេតុផលថា របាយការណ៏ហិរញ្ញវត្ថុទាំងមូលមិនមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំឬការភាន់ច្រឡំ ហើយធ្វើការចេញផ្សាយរបាយការណ៏របស់សវនករដែលរួមមានមតិយោបល់របស់យើងខ្ញុំ។ ការធានាអះអាងដែលសមហេតុផល គឺជាការធានាអះអាងកម្រិតខ្ពស់មួយ ប៉ុន្តែមិនមែនជាការធានាថាការងារសវនកម្ម ដែលប្រព្រឹត្តទៅដោយអនុលោមតាម CISAs តែងតែរកឃើញកំហុសឆ្គងជាសារវន្តដែលមាននោះទេ។ កំហុសឆ្គងអាចកើតចេញពីការក្លែងបន្លំ ឬការភាន់ច្រឡំ និងត្រូវបានចាត់ទុកថាជាសារវន្ត ប្រសិនបើកំហុសឆ្គងទាំងអស់នោះ តែមួយ ឬបញ្ចូលគ្នាជារួម អាចមានឥទ្ធិពលលើការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច របស់អ្នកប្រើប្រាស់ដោយផ្អែកលើមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ជាផ្នែកមួយនៃការងារសវនកម្មដែលអនុលោមតាម CISAs យើងខ្ញុំបានធ្វើការវិនិច្ឆ័យ និងរក្សានូវចម្ងល់ប្រកប ដោយវិជ្ជាជីវៈក្នុងដំណើរការសវនកម្ម។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃហានិភ័យនៃកំហុសឆ្គងជាសារវន្ត នៃរបាយការណ៍ហិរញ្ញវត្ថុ ដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំប្រឌិត និងអនុវត្តនិតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ ហើយប្រមូលភស្តុតាងសវនកម្មឲ្យបានគ្រប់គ្រាន់ និងសមស្របសម្រាប់ផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ មានកម្រិតខ្ពស់ជាងហានិភ័យដែលមិនអាចរឃើញកំហុសឆ្គងដែលបណ្តាលមកពីការភាន់ច្រឡំ ព្រោះថាការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការបន្លំ ការលុបចេញដោយចេតនា ការរាយការណ៍មិនត្រឹមត្រូវ ឬមិនគោរពតាមប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធនឹងការងារសវនកម្ម ដើម្បីបង្កើតជានីតិវិធី សវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនទេ។
- វាយតម្លៃភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញដែលជាប់ទាក់ទងផ្សេងទៀតដែលធ្វើឡើងដោយគណៈគ្រប់គ្រង។
- ធ្វើសេចក្តីសន្និដ្ឋាន លើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្ម នៅក្នុងប្រព័ន្ធគណនេយ្យដោយគណៈគ្រប់គ្រង និងតាមរយៈភស្តុតាងសវនកម្មដែលទទួលបាន យើងខ្ញុំធ្វើការសន្និដ្ឋាន ថាតើមានវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្តទាក់ទងនឹងព្រឹត្តិការណ៍ ឬកាលៈទេសៈទាំងឡាយណាដែលនាំឲ្យមានការសង្ស័យជាសារវន្ត ទៅលើនិរន្តរភាពនៃដំណើរការអាជីវកម្មរបស់ក្រុមហ៊ុនទេ។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានវត្តមាននៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំតម្រូវឲ្យទាញចំណាប់អារម្មណ៍ក្នុងរបាយការណ៍សវនករ លើកំណត់សម្គាល់លើការពាក់ព័ន្ធ ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬ ប្រសិនបើកំណត់សម្គាល់នេះពុំមានលក្ខណៈគ្រប់គ្រាន់ទេនោះ យើងខ្ញុំនឹងធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺពឹងផ្អែកលើភស្តុតាង សវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍សវនករ។ តែទោះជាយ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬកាលៈទេសៈនាពេលអនាគត ក៏អាចបង្កឲ្យក្រុមហ៊ុនមិនអាចបន្តនិរន្តរភាពរបស់អាជីវកម្មបានផងដែរ។
- វាយតម្លៃការបង្ហាញទូទៅ មាតិកា និងខ្លឹមសារក្នុងរបាយការ-ណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងកំណត់សម្គាល់ផ្សេងៗ និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុ តំណាងឲ្យប្រតិបត្តិការណ៍ និងព្រឹត្តិការណ៍ដែលជាមូលដ្ឋាន ដើម្បីសម្រេចបាននូវការបង្ហាញដ៏ត្រឹមត្រូវឬទេ។

ក្នុងចំណោមបញ្ហាដទៃទៀត យើងខ្ញុំបានធ្វើការទំនាក់ទំនងជាមួយអ្នកទទួលបន្ទុកលើអភិបាលកិច្ចអំពីវិសាលភាពដែលបានគ្រោងទុក និងពេលវេលានៃការងារសវនកម្ម និងរបកគំហើញសំខាន់ៗ រួមបញ្ចូលផងដែរនូវកង្វះខាតសំខាន់ៗទាំងឡាយទៅលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

Maria Cristina M. Calimbas

Ernst & Young (Cambodia) Ltd.
ក្រុមហ៊ុនគណនេយ្យករជំនាញ
សវនករប្រតិស្រុត

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៨

# តារាងតុល្យការ

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧

| | ២០១៧ | | ២០១៦ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ទ្រព្យសកម្ម | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤.១០០ | ១៦.៥៥២ | ៣.៦៨៩ | ១៤.៨៩២ |
| ប្រាក់បញ្ញើនៅធនាគារ | ១.៤៩៥.១៨៥ | ៦.០៣៦.០៦២ | ៧.១៧១.១៦៧ | ២៨.៩៥០.០០១ |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់ | ១៨០.១០២ | ៧២៧.០៧២ | ១៨០.១០២ | ៧២៧.០៧២ |
| ឥណទានផ្តល់ដល់អតិថិជន | ១៩.៦១៧.៥៧៧ | ៧៩.១៩៦.១៥៨ | ១៩.១៤១.៧៣៣ | ៧៧.២៧៥.១៧៦ |
| ទ្រព្យសកម្មផ្សេងៗ | ៧៣១.៧៦៦ | ២.៩៥៤.១៣៨ | ៤៩៦.៤៣១ | ២.០០៤.០៩២ |
| ទ្រព្យ និងបរិក្ខារ | ២៥៦.៩៦៥ | ១.០៣៧.៣៦៨ | ១៤៩.៥៣១ | ៦០៣.៦៥៧ |
| ទ្រព្យសកម្មអរូបី | ៦៦.២៩០ | ២៦៧.៦១៣ | - | - |
| ទ្រព្យសកម្មពន្ធពន្យារសុទ្ធ | ៨៤.២៤៧ | ៣៤០.១០៥ | ១១៤.៨៥៨ | ៤៦៣.៦៨២ |
| **សរុបទ្រព្យសកម្ម** | **២២.៤៣៦.២៣២** | **៩០.៥៧៥.០៦៨** | **២៧.២៥៧.៥១១** | **១១០.០៣៨.៥៧២** |
| បំណុល និងមូលធន | | | | |
| បំណុល | | | | |
| ប្រាក់កម្ចី | ១៥.១៧៨.៨៦៦ | ៦១.២៧៧.០៨២ | ១៩.៧៥៦.៣០៣ | ៧៩.៧៥៦.១៩៥ |
| បំណុលផ្សេងៗ | ៦៥៨.២៦៥ | ២.៦៥៧.៤១៦ | ៨១៣.០៦៤ | ៣.២៨២.៣៣៩ |
| សំវិធានធនសម្រាប់ពន្ធ | | | | |
| លើប្រាក់ចំណេញ | ២.៩៥៨ | ១១.៩៤១ | ១៤៦.៨៤៧ | ៥៩២.៨២២ |
| **សរុបបំណុល** | **១៥.៨៤០.០៨៩** | **៦៣.៩៤៦.៤៣៩** | **២០.៧១៦.២១៤** | **៨៣.៦៣១.៣៥៦** |
| មូលធនម្ចាស់ភាគហ៊ុន | | | | |
| ដើមទុន | ៣.៦០២.០៣៣ | ១៤.៥៤១.៤០៧ | ២.៩២៦.៩៥៥ | ១១.៨១៦.១១៧ |
| បុព្វលាភដើមទុន | ៨៧៩.៤៨២ | ៣.៥៥០.៤៦៩ | ៣១២.៤១៦ | ១.២៦១.២២៣ |
| ប្រាក់តម្កល់សម្រាប់ទិញមូលធន | | | | |
| ភាគហ៊ុននាពេលអនាគត | - | - | ១.២៤២.១៤៤ | ៥.០១៤.៥៣៦ |
| ប្រាក់ចំណេញរក្សាទុក | ២.១១៤.៦២៨ | ៨.៥៣៦.៧៥៣ | ២.០៥៩.៧៨២ | ៨.៣១៥.៣៤០ |
| **សរុបមូលធន** | **៦.៥៩៦.១៤៣** | **២៦.៦២៨.៦២៩** | **៦.៥៤១.២៩៧** | **២៦.៤០៧.២១៦** |
| **សរុបបំណុលនិងមូលធន** | **២២.៤៣៦.២៣២** | **៩០.៥៧៥.០៦៨** | **២៧.២៥៧.៥១១** | **១១០.០៣៨.៥៧២** |



# របាយការណ៍លទ្ធផល

នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៧ និងសម្រាប់ការិយបរិច្ឆេទបញ្ចប់

| | ២០១៧ | | ២០១៦ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ចំណូលប្រតិបត្តិការ** | | | | |
| ចំណូលពីការប្រាក់ | ៣.២៨១.៩៧៨ | ១៣.២៤៩.៣៤៥ | ៣.៩១៣.២៦៩ | ១៥.៧៩៧.៨៦៧ |
| ចំណាយការប្រាក់ | (១.៥៣៧.៧៦៧) | (៦.២០៧.៩៦៥) | (១.៦៦០.៤៩៥) | (៦.៧០៣.៤១៨) |
| **ចំណូលពីការប្រាក់សុទ្ធ** | **១.៧៤៤.២១១** | **៧.០៤១.៣៨០** | **២.២៥២.៧៧៤** | **៩.០៩៤.៤៤៩** |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | ៤១៤.៥៤៧ | ១.៦៧៣.៥២៦ | ២៨៧.៣៩២ | ១.១៦០.២០១ |
| **ចំណូលប្រតិបត្តិការ** | **២.១៥៨.៧៥៨** | **៨.៧១៤.៩០៦** | **២.៥៤០.១៦៦** | **១០.២៥៤.៦៥០** |
| សំវិធានធនលើឥណទាន | | | | |
| ខាតបង់ | (២៦៤.៥០៣) | (១.០៦៧.៧៩៩) | (៥៦៣.៤៩១) | (២.២៧៤.៨១៣) |
| ចំណាយទូទៅ និងរដ្ឋបាល | (១.៧៧១.៧០១) | (៧.១៥២.៣៥៧) | (១.៤៨១.៩៧៦) | (៥.៩៨២.៧៣៧) |
| **ប្រាក់ចំណេញមុនដកពន្ធ** | **១២២.៥៥៤** | **៤៩៤.៧៥០** | **៤៩៤.៦៩៩** | **១.៩៩៧.១០០** |
| ពន្ធលើប្រាក់ចំណេញ | (៦៧.៧០៨) | (២៧៣.៣៣៧) | (១២៦.៤៦៥) | (៥១០.៥៣៩) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់** | | | | |
| **ការិយបរិច្ឆេទ** | **៥៤.៨៤៦** | **២២១.៤១៣** | **៣៦៨.២៣៤** | **១.៤៨៦.៥៦១** |

# របាយការណ៍បម្រែបម្រួលក្នុងមូលធន

នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៧ និងសម្រាប់ការិយបរិច្ឆេទបញ្ចប់

| | ដើមទុន | បុព្វលាភដើមទុន | ប្រាក់តម្កល់សម្រាប់ទិញមូលធនភាគហ៊ុននាពេលអនាគត | ប្រាក់ចំណេញរក្សាទុក | សរុប |
|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ | ២.៩២៦.៩៥៥ | ៣១២.៤១៦ | ១.២៤២.១៤៤ | ២.០៥៩.៧៨២ | ៦.៥៤១.២៩៧ |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | ៥៤.៨៤៦ | ៥៤.៨៤៦ |
| ការបោះផ្សាយដើមទុនបន្ថែម | ៦៧៥.០៧៨ | ៥៦៧.០៦៦ | (១.២៤២.១៤៤) | - | - |
| **គិតត្រឹមថ្ងៃ ៣១ ខែ ធ្នូ ឆ្នាំ ២០១៧** | **៣.៦០២.០៣៣** | **៨៧៩.៤៨២** | - | **២.១១៤.៦២៨** | **៦.៥៩៦.១៤៣** |
| **សមមូលពាន់រៀល** | **១៤.៥៤១.៤០៧** | **៣.៥៥០.៤៦៩** | - | **៨.៥៣៦.៧៥៣** | **២៦.៦២៨.៦២៩** |
| គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ | ២.២៨៩.៣៧០ | ៣១២.៤១៦ | ១.៨៧៩.៧២៩ | ១.៦៩១.៥៤៨ | ៦.១៧៣.០៦៣ |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | ៣៦៨.២៣៤ | ៣៦៨.២៣៤ |
| ការបោះផ្សាយដើមទុនបន្ថែម | ៦៣៧.៥៨៥ | - | (៦៣៧.៥៨៥) | - | - |
| **គិតត្រឹមថ្ងៃ ៣១ ខែ ធ្នូ ឆ្នាំ ២០១៦** | **២.៩២៦.៩៥៥** | **៣១២.៤១៦** | **១.២៤២.១៤៤** | **២.០៥៩.៧៨២** | **៦.៥៤១.២៩៧** |
| **សមមូលពាន់រៀល** | **១១.៨១៦.១១៧** | **១.២៦១.២២៣** | **៥.០១៤.៥៣៥** | **៨.៣១៥.៣៤០** | **២៦.៤០៧.២១៦** |



# របាយការណ៍លំហូរសាច់ប្រាក់

នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៧ និងសម្រាប់ការិយបរិច្ឆេទបញ្ចប់

| | ២០១៧ | | ២០១៦ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ** | (៨៦៥.៤៨០) | (៣.៤៩៣.៩៤៦) | ២.១៨៦.៤២៤ | ៨.៨២៦.៥៩៣ |
| **សកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | (២០១.៤៣១) | (៨១៣.១៧៧) | (១១១.៦៧៦) | (៤៥០.៨៣៦) |
| ការទិញទ្រព្យសកម្មអរូបី | (៦៧.៥១៨) | (២៧២.៥៧០) | - | - |
| សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យ និងបរិក្ខារ | - | - | ៥២ | ២១០ |
| ប្រាក់បញ្ញើមានកាលកំណត់ | ១.០០០.០០០ | ៤.០៣៧.០០០ | (១.០០០.០០០) | (៤.០៣៧.០០០) |
| លំហូរសាច់ប្រាក់សុទ្ធបានពី (ប្រើប្រាស់ក្នុង) សកម្មភាពវិនិយោគ | **៧៣១.០៥១** | **២.៩៥១.២៥៣** | **(១.១១១.៦២៤)** | **(៤.៤៨៧.៦២៦)** |
| **សកម្មភាពហិរញ្ញវត្ថុ** | | | | |
| សាច់ប្រាក់ទូទាត់សងប្រាក់កម្ចី | (៤.៥៧៧.៤៣៧) | (១៨.៤៧៩.១១៣) | (១.៦៨២.០៦៨) | (៦.៧៩០.៥០៩) |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | - | - | ៥.០០០.០០០ | ២០.១៨៥.០០០ |
| លំហូរសាច់ប្រាក់សុទ្ធបានពី (ប្រើប្រាស់ក្នុង) សកម្មភាពហិរញ្ញវត្ថុ | **(៤.៥៧៧.៤៣៧)** | **(១៨.៤៧៩.១១៣)** | **៣.៣១៧.៩៣២** | **១៣.៣៩៤.៤៩១** |
| **ការកើនឡើង/(ថយចុះ)នូវសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | (៤.៧១១.៨៦៦) | (១៩.០២១.៨០៦) | ៤.៣៩២.៧៣២ | ១៧.៧៣៣.៤៥៩ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី ១ ខែមករា** | ៦.០៨១.១១៣ | ២៤.៥៤៩.៤៥៣ | ១.៦៨៨.៣៨១ | ៦.៨៣៧.៩៤៣ |
| **ភាពលំអៀងនៃការប្តូររូបិយប័ណ្ណ** | - | - | - | (២១.៩៤៩) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី ៣១ ខែធ្នូ** | **១.៣៦៩.២៤៦** | **៥.៥២៧.៦៤៧** | **៦.០៨១.១១៣** | **២៤.៥៤៩.៤៥៣** |





"ហ្វីស ហ្វាយនែន មិនរើសអើងខ្ញុំទេ ក្នុងការផ្ដល់កម្ចីដល់ខ្ញុំដើម្បីសង់ផ្ទះ"

លោក ប៉ិច ជី ជាអតីតទាហានក្នុងកងយុទ្ធពលខេមរ-ភូមិន្ទ។ ក្នុងពេលប្រយុទ្ធជាមួយកងកម្លាំងខ្មែរក្រហមដែលនៅសេសសល់ ក្នុងពាក់កណ្ដាលទសវត្សរ៍ទី ៩០ គាត់បានរងគ្រោះដោយការដើរជាន់មីន ដែលធ្វើឱ្យគាត់ពិការជើងស្ដាំ។

បើទោះបីជាមានរឿងមិនល្អនេះបានកើតឡើង គាត់បានប្រឹងប្រែងធ្វើការដោយចិញ្ចឹមជ្រូក និងផលិតស្រាអង្ករដើម្បីលក់ជាមួយភរិយារបស់គាត់គឺ លោកស្រី អឿន យឿន។ ក្នុងពេលដែលត្រូវចិញ្ចឹមកូនប្រុសបីនាក់ និងកូនស្រីម្នាក់ គាត់ត្រូវប្រើពេលស្ទើរតែពេញមួយជីវិតរបស់គាត់ក្នុងការ សន្សំប្រាក់ដើម្បីសាងសង់ផ្ទះសម្រាប់គ្រួសាររបស់គាត់ក្នុងស្រុកភ្នំព្រឹក ខេត្តបាត់ដំបង។

ទោះបីយ៉ាងណា គាត់មិនទាន់មានប្រាក់សន្សំគ្រប់គ្រាន់នៅឡើយដើម្បីសង់ផ្ទះ ហើយបន្ទាប់ពីអ្នកជិតខាងម្នាក់បានណែនាំគាត់អំពី ហ្វីស ហ្វាយនែន គាត់ និងភរិយាបានសម្រេចចិត្តជ្រើសរើសយកកម្ចីសម្រាប់សាងសង់ផ្ទះ។ ជាមួយនឹងប្រាក់ចំណូល ៤៩៦ ដុល្លារ ក្នុងមួយខែ ក្នុងខែមេសា ឆ្នាំ២០១៧ ពួកគាត់អាចទទួលបានកម្ចីចំនួន ៥០០០ ដុល្លារ ដែលអាចបង់សងក្នុងរយៈពេល ១២០ខែ។

លោក ប៉ិច ជី និយាយថា គាត់ពេញចិត្តនឹងការបង់សងក្នុងរយៈពេលវែងលើកម្ចីដែលអាចធ្វើឱ្យគាត់មានលទ្ធភាពបង់ និងភាពងាយស្រួលនៃការអនុម័តឥណទាន។ គាត់ថ្លែងអំណរគុណជាពិសេសថា ៖ " ហ្វីស ហ្វាយនែន មិនរើសអើងខ្ញុំទេ ក្នុងការផ្ដល់កម្ចីដល់ខ្ញុំដើម្បីសង់ផ្ទះ "

# ក្រុមប្រឹក្សាភិបាលនិងថ្នាក់ដឹកនាំ



## LEE-ANNE PITCAITHLY
### ប្រធានក្រុមប្រឹក្សាភិបាល

លោកស្រី Lee-Anne Pitcaithly បានចូលរួមជាមួយ ហ្វីស ហ្វាយនែន ក្នុងឆ្នាំ២០១៤ ជាប្រធានក្រុមប្រឹក្សាភិបាល ជាមួយបទពិសោធន៍ជាលក្ខណៈអន្តរជាតិ រយៈពេល៨ឆ្នាំ ក្នុងវិស័យសេវាហិរញ្ញវត្ថុចល័តដើម្បីបម្រើដល់ជនក្រីក្រ ។ រួមជាមួយជំនាញខាងផ្នែកគ្រប់គ្រងពាណិជ្ជកម្ម និងបទ-ពិសោធន៍ ក្នុងធនាគារពាណិជ្ជ និងក្រុមហ៊ុនផ្នែកទូរគមនាគមន៍ លោកស្រី Lee-Anne បាននាំមកនូវចំណេះនិងជំនាញជាច្រើនទៅក្នុងមុខតំណែងរបស់គាត់។ លោកស្រី Lee-Anne ធ្លាប់កាន់តួនាទីជាច្រើនក្នុងតំណែងជាថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន វីង (កម្ពុជា) និង Grameen Foundation (យូហ្កាន់ដា)។ ដោយមានទីលំនៅក្នុងប្រទេសកម្ពុជា លោកស្រី Lee-Anne នូវតែបន្តការងារជាអ្នកប្រឹក្សាយោបល់ជាលក្ខណៈអន្តរជាតិសម្រាប់សេវាហិរញ្ញវត្ថុឌីជីថល។



## TALMAGE PAYNE
### អភិបាល
#### តំណាងម្ចាស់ភាគហ៊ុន ហ្វីស ហូម ទីអិលស៊ី

លោក Talmage Payne ជាសហគ្រិន និងអ្នកមានគំនិតច្នៃប្រឌិតមួយរូប ហើយសព្វថ្ងៃជាប្រធាននៃអង្គការសេចក្ដីសង្ឃឹមពិភពលោកអន្តរជាតិប្រចាំនៅកម្ពុជា។ គាត់គឺជាស្ថាបនិក ហ្វីស ហ្វាយនែន និងអាជីវកម្មសង្គមជាច្រើនទៀត។ គាត់បានចំណាយពេលស្ទើរមួយជីវិតរបស់គាត់រស់ នៅទ្វីបអាស៊ី ដើម្បីធ្វើការទាំងក្នុងស្ថាប័នរកប្រាក់ចំណេញ និងស្ថាប័នមិនរកប្រាក់ចំណេញ ដែលផ្ដល់ភាពវិជ្ជមានដល់សង្គម ។ គាត់ធ្លាប់ជានាយកប្រតិបត្តិនៃអង្គការ Hagar International (ការការពារ និង ការធ្វើឲ្យប្រសើរឡើងដល់អ្នកដែលរួចផុតពីការជួញដូរមនុស្ស) និងបានជួយបង្កើត Hagar ចំនួន ៩ប្រទេសដោយប្រើម៉ូដែល មានទាំងការរកប្រាក់ចំណេញ និងមិនរកប្រាក់ចំណេញ ។ លោកធ្លាប់ជានាយកអង្គការទស្សនៈពិភពលោកកម្ពុជា និងជាប្រធានស្ថាបនិក វីសិនហ្វាន់កម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ការងារមនុស្សធម៌របស់លោកជាច្រើនលើកតាមរយៈការបំពាក់មេដាយ ថ្នាក់មនុស្សជាតិពីរដង និងងារសហមេត្រី។ លោក បានសិក្សាមុខវិជ្ជាអភិវឌ្ឍន៍សេដ្ឋកិច្ចនៅសាកលវិទ្យាល័យ Wheaton College។



## NICHOLAS LAZOS
### អភិបាល
#### តំណាងម្ចាស់ភាគហ៊ុន Insitor Fund

លោក Nicholas Lazos គឺជាសហស្ថាបនិក និងជានាយកនៃក្រុមហ៊ុន Insitor Impact Asia Fund លោក Nicholas បានធ្វើការនៅភាគខាងត្បូង និង អាស៊ីអាគ្នេយ៍អស់រយៈពេល៩ឆ្នាំ ព្រមទាំងបានជួយសហគ្រាសសង្គម ក្នុងដំណាក់កាលចាប់ផ្ដើម ។ លោក Nicholas ទទួលខុសត្រូវលើវិនិយោគទុនធំៗ និងមានតួនាទីជាអភិបាលនៅក្នុងក្រុមហ៊ុនដែល Insitor បានវិនិយោគ។ មុននឹងចូលបម្រើការនៅ Insitor លោក Nicholas គឺជាប្រធានចាត់ការទូទៅ របស់ក្រុមហ៊ុនដែលផ្ដល់ដំណោះស្រាយ ខាងគេហដ្ឋានដល់អ្នកដែលមានចំណូលទាប មុនគេបង្អស់នៅកម្ពុជា។ លោកបានរៀបចំចាត់ចែងតាំងពីដំបូង និងអភិវឌ្ឍរហូតមានប្រតិបត្តិការពេញលេញ។ គាត់ទទួលបានសញ្ញាប័ត្រពីរគឺ ផ្នែកគណិតវិទ្យានៅក្នុងកម្មវិធីវិទ្យាសាស្ត្រសង្គមពីសាកលវិទ្យាល័យ Northwestern University ។



## ក្រុមប្រឹក្សាភិបាល



## ONG TEONG HOON
### អភិបាល
#### តំណាងម្ចាស់ភាគហ៊ុន Phillip Capital

លោក Ong Teong Hoon មានបទពិសោធន៍ជាង ៣០ឆ្នាំ ក្នុងវិស័យធនាគារនៅអាស៊ី និងបទ-ពិសោធន៍ប៉ុន្មានឆ្នាំចុងក្រោយក្នុងវិស័យមីក្រូ-ហិរញ្ញវត្ថុ។ លោក Teong Hoon គឺជានាយកប្រតិបត្តិជាន់ខ្ពស់ប្រចាំក្រុមហ៊ុន Phillip Capital ដែលជាក្រុមហ៊ុននាំមុខមួយនៅក្នុងអាស៊ី ហើយបច្ចុប្បន្នជាអភិបាលនៅធនាគារ Phillip ក្នុងប្រទេសកម្ពុជា និងជាអភិបាលក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រេឌីត នៅកម្ពុជា ។

លោកជាប្រធានក្រុមប្រឹក្សាភិបាលសាលា Methodist ក្នុងប្រទេសកម្ពុជា និងមានតួនាទីជាថ្នាក់ដឹកនាំកំពូលនៃកម្មវិធី Youth and Detention Rehabilitation Program ។ លោក Teong Hoon ក៏ជាសមាជិកស្ថាបនិកក្រុមប្រឹក្សាភិបាលរបស់ ហ្វីស ហ្វាយនែន និងបានធ្វើដំណើរជាមួយយើងឆ្លងកាត់ទាំងភាពលំបាក ការរីកចម្រើនខ្លាំង និងជ័យជំនះ។ គាត់ក៏ជាសមាជិកនៃវិទ្យាស្ថានធនាគារក្នុងទីក្រុងឡុងដ៍ផងដែរ (The Chartered Institute of Bankers in London) ។



## FAY CHETNA
### អភិបាល
#### តំណាងម្ចាស់ភាគហ៊ុន Norfund

អ្នកស្រី Fay Chetna ជានាយិកាផ្នែកវិនិយោគ និងជាប្រធាននៃ Norfund ប្រចាំនៅអាស៊ី ។ អ្នកស្រីមានតួនាទីក្នុងការគ្រប់គ្រង និងដឹកនាំផលបត្ររបស់ Norfund នៅអាស៊ី។ មុនមកកាន់ Norfund អ្នកស្រីបានបម្រើការងារនៅសហប្រតិ-បត្តិការហិរញ្ញវត្ថុអន្តរជាតិនិងធនាគាពិភពលោក។ អ្នកស្រីក៏មានបទពិសោធន៍ក្នុងវិស័យអភិវឌ្ឍន៍ហិរញ្ញវត្ថុតាមបណ្ដាប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ អាព្រិច អាមេរិកឡាទីន និងអឺរ៉ុបខាងកើត។ អ្នកស្រីបានបញ្ចប់ការសិក្សារពីសាកវិទ្យាល័យ Johns Hopkins ផ្នែកសិក្សារអន្តរជាតិជាន់ខ្ពស់។



## BRAD JONES
### សមាជិកក្រុមប្រឹក្សាឯករាជ្យ

លោក Brad Jones ធ្លាប់ជាអ្នកគ្រប់គ្រងជាន់ខ្ពស់ និង ជានាយកប្រតិបត្តិក្នុងវិស័យធនាគារ និងការទូទាត់នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក មជ្ឈឹមបូព៌ានិងប្រទេសអូស្ត្រាលី។ បទពិសោធន៍របស់លោករួមមានការចាប់ផ្ដើមអាជីវកម្មក្នុងទីផ្សារកំពុងអភិវឌ្ឍន៍ដែលមានការលំបាក រហូតដល់ការគ្រប់គ្រងប្រតិបត្តិការក្នុងធនាគារអន្តរជាតិ។ បច្ចុប្បន្ន លោក Brad គឺជានាយកក្រុមហ៊ុន Wave Money ក្នុងការផ្ដល់សេវាផ្ទេរប្រាក់ចល័ត ដែលក្រុមហ៊ុននេះបានបណ្ដាក់ទុន នៅក្នុងប្រទេសភូមា រវាងក្រុមហ៊ុន Telenor នឹងធនាគារ Yoma ។ កន្លងមក លោកគឺជាស្ថាបនិកនាយកគ្រប់គ្រងរបស់ក្រុមហ៊ុន វីង និងជាថ្នាក់ដឹកនាំជាន់ខ្ពស់ ក្នុងការច្នៃប្រឌិតទៅលើប្រព័ន្ធទូរស័ព្ទចល័ត សម្រាប់ផលិតផល Visa ។ បន្ថែមលើបទពិសោធន៍ក្រុមហ៊ុនដ៏ទូលំទូលាយ គាត់ធ្លាប់ផ្ដល់ការប្រឹក្សាដល់ World Bank Group, Grameen Foundation, និង DFID សម្រាប់ផ្នែកសេវាហិរញ្ញវត្ថុ ឌីជីថល។ លោកទទួលបានបរិញ្ញាបត្រពាណិជ្ជកម្មពីសាកលវិទ្យាល័យ Griffith និងសញ្ញាបត្រអនុបណ្ឌិតពីសា-កលវិទ្យាល័យ University of Queensland ។

# ក្រុមប្រឹក្សាភិបាល



## លោក វិចិត្រ វណ្ណារដ្ឋ

### អភិបាល

### តំណាងម្ចាស់ភាគហ៊ុន CLDF

លោក វិចិត្រ វណ្ណារដ្ឋ បានចូលរួមជាអភិបាលតំណាងម្ចាស់ភាគហ៊ុនរបស់ ហ៊ឹស ហ្វាយនែន នាឆ្នាំ២០១៦។ លោកបានបម្រើការងារក្នុងវិស័យស្ថាប័នហិរញ្ញវត្ថុជាង ១០ឆ្នាំដោយមានបទពិសោធន៍ក្នុងវិស័យធនាគារអន្តរជាតិ និងបទពិសោធន៍វិនិយោគពីសហរដ្ឋអាមេរិក អឺរ៉ុប និងកម្ពុជា។ សព្វថ្ងៃនេះលោក វណ្ណារដ្ឋ ជាប្រធានគ្រប់គ្រងការវិនិយោគនៃ Emerging Markets Investment Advisors (EMIA) ដែលជាក្រុមហ៊ុនឯកជនរបស់សឹង្ហបុរី ផ្តល់សេវាប្រឹក្សាយោបល់វិនិយោគ។ មុនមកកាន់ទីនេះ គាត់ធ្លាប់មានតួនាទីជាច្រើនដូចជា នាយកប្រតិបត្តិប្រធានប្រឹក្សាសហប្រតិបត្តិការហិរញ្ញវត្ថុនៅ Cana Securities, the investment banking arm of Canadia Investment Holding Plc.

លោក វណ្ណារដ្ឋ បានបញ្ចប់អនុបណ្ឌិតផ្នែកគ្រប់គ្រងនៅសាកលវិទ្យាល័យ Harvard និងបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកធនាគារ និងហិរញ្ញវត្ថុ ពីសាលាពាណិជ្ជសាស្ត្រអឺរ៉ុប ESCP ។ លោកក៏ជាសមាជិកនៃ CPA របស់ អូស្ត្រាលី ផងដែរ។



## PAUL FREER

### សមាជិកក្រុមប្រឹក្សាឯករាជ្យ

លោក Paul Freer មានបទពិសោធន៍ក្នុងតំណែងជាន់ខ្ពស់ជាង ២០ឆ្នាំជាមួយធនាគារអន្តរជាតិ និងមានប្រវត្តិទទួលបានជោគជ័យក្នុងការគ្រប់គ្រងគំរោង ការអប់រំ ជាមួយវិស័យអង្គការមិនរកប្រាក់ចំណេញក្នុងប្រទេសកម្ពុជា ។
លោក Paul បានចាប់ផ្តើមអាជីពធនាគារដំបូង ក្នុងប្រទេសអង់គ្លេស មុនពេលចំណាយពេល១៥ឆ្នាំទៀតធ្វើការក្នុងប្រទេសកម្ពុជា និងប្រទេសឡាវក្នុងមុខដំណែងអ្នកគ្រប់គ្រងជាន់ខ្ពស់ ក្នុងអង្គការទាំងរកប្រាក់ចំណេញ និងមិនរកប្រាក់ចំណេញ ។ លោក Paul ធ្លាប់ជានាយកប្រតិបត្តិធនាគារ Standard Charted Bank ក្នុងប្រទេសកម្ពុជា នាយកគ្រប់គ្រងធនាគារ Phongsavanh Bank ក្នុងប្រទេសឡាវ និងជានាយកផ្នែក Retail Banking នៃធនាគារ ANZ Royal Bank (Cambodia)។ គាត់ក៏បានរួមចំណែកក្នុងការបង្កើតធនាគារ MARUHAN Japan BANK ក្នុងប្រទេសកម្ពុជាដោយគាត់បានបំរើការជាអគ្គនាយករង និងជាអ្នកចាត់ការទូទៅ។
លោក Paul គឺជាសមាជិកគណៈកម្មាធិការផ្នែកហិរញ្ញវត្ថុ និងសម្ភារៈបរិក្ខាររបស់សាលា International School of Phnom Penh និងជាអ្នកប្រឹក្សាឯករាជ្យលើវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុជាមួយធនាគារពិភពលោក ក៏ដូចជាអង្គការដ៏ទៃទៀត។
លោក Paul ទទួលបានសញ្ញាបត្រអនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្មពីសាកលវិទ្យាល័យ Southampton Business School របស់ប្រទេសអង់គ្លេស។



## JOSHUA MORRIS

### អ្នកអង្កេត

### តំណាងម្ចាស់ភាគហ៊ុន CLDF

លោក Joshua Morris ជាដៃគូរស្ថាបនិកនិងជានាយកគ្រប់គ្រងនៃ Emerging Markets Investments (EMI) ជាអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគដែលមានមូលដ្ឋាននៅប្រទេសកម្ពុជា និងគ្រប់គ្រង Cambodia-Laos Development Fund ។ មុនពេលបង្កើត EMI លោក Joshua បានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍វិស័យឯកជន និងផ្តល់ប្រឹក្សាអាជីវកម្មនៅក្នុងអាស៊ីអាគ្នេយ៍ តាមរយៈតួនាទីរបស់លោកជាសហស្ថាបនិកក្រុមហ៊ុន Emerging Markets Consulting ដែលជាក្រុមហ៊ុនប្អូនរបស់ក្រុមហ៊ុន EMI ។
មុនពេលប្តូរមករស់នៅកម្ពុជាក្នុងឆ្នាំ ២០០៤ លោក Joshua មានការងារជាអ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកទីផ្សារ និង អភិវឌ្ឍន៍សាជីវកម្មនៃក្រុមហ៊ុនបច្ចេកវិទ្យា ដែលទើបចាប់ផ្តើម និង NASDQ ជាអាជីវកម្ម ពាណិជ្ជកម្មអេឡិចត្រូនិចដែលមានចុះបញ្ជីទីផ្សារភាគហ៊ុន ។
លោក Joshua ទទួលបានសញ្ញាបត្រអនុបណ្ឌិតពីសាកលវិទ្យាល័យ Harvard Business School ឆ្នាំ១៩៩៨ និងសញ្ញាបត្របរិញ្ញាបត្រកិត្តិយសពី Harvard University ក្នុងឆ្នាំ១៩៩២ ។





អ្នកស្រី អឿន យ៉ន កំពុងរៀបចំចំណីជ្រូក
អតិថិជន ហ៊ឹស ហ្វាយនែន
ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

# គណៈគ្រប់គ្រង













## ជុន សុថានី
### អគ្គនាយិកាប្រតិបត្តិ

លោកស្រី ជុន សុថានី បានចាប់ផ្តើមអាជីពជាមួយ អង្គការទស្សនៈពិភពលោក ជាសវនករផ្ទៃក្នុង នៅក្នុងឆ្នាំ ២០០២។ ចាប់តាំងពីពេលនោះមក លោកស្រី មានការរីកចម្រើនយ៉ាងលឿនជាមួយ តួនាទីជាច្រើន រួមមានការគ្រប់គ្រងការបង្កើត គម្រោង ការបង្កើតសំណើរ (Propsoal Develo pment) ការពិនិត្យការរីកចម្រើន និងការកសាង ទំនាក់ទំនងជាមួយម្ចាស់ជំនួយ។

នៅឆ្នាំ២០០៧ លោកស្រី បានក្លាយជាប្រធានផ្នែក អភិវឌ្ឍន៍ពាណិជ្ជកម្មនៃ វីសិនហ្វាន់ កម្ពុជា ដែល លោកស្រីទទួលខុសត្រូវផ្នែករកមូលនិធិ ផ្នែកទីផ្សារ ផ្នែកទំនាក់ទំនង និងអភិវឌ្ឍន៍ផលិតផល ។ ឆ្នាំ ២០០៨ លោកស្រីផ្លាស់ទៅក្រុមហ៊ុន វីង ដែលនៅ ទីនោះ លោកស្រីបានបង្កើតផែនការយុទ្ធសាស្ត្រ និងគ្រប់គ្រងការលក់ រួមទាំងការលើកទឹកចិត្តនិង ពង្រីកភ្នាក់ងារលក់ជាង៩០០នាក់ ។ លោកស្រី សុថានីបានចូលបម្រើការជាមួយ ហ្វីស ហ្វាយនែន នៅឆ្នាំ ២០១១ ជានាយិកាផ្នែកហិរញ្ញវត្ថុ ហើយ ត្រូវបានតែងតាំងជាអគ្គនាយិកាប្រតិបត្តិ នៅខែ សីហា ឆ្នាំ ២០១៤ ។

លោកស្រី សុថានី បានទទួលបរិញ្ញាបត្រគ្រប់គ្រង ផ្នែកគណនេយ្យ និងបានបន្តអនុបណ្ឌិតអភិវឌ្ឍអង្គ-ភាពក្នុងការគ្រប់គ្រងកម្ចីខ្នាតតូច ។

## នីន និត្យា
### នាយកហិរញ្ញវត្ថុ

លោក និត្យា បានបញ្ចប់ផ្នែក រដ្ឋបាលអាជីវកម្ម ពី សាកលវិទ្យាល័យ កាលីហ្វ័រនៀរ នៅ Berkeley ហើយបានទទួលអាជ្ញាបណ្ណបញ្ជាក់ជាគណនេយ្យ-ករសាធារណៈ (CPA) ក្នុងឆ្នាំ ២០០៩ ។

ដោយរួមបញ្ចូលរយៈពេលបំពេញការងារ ២ឆ្នាំ ជាមួយក្រុមហ៊ុន Fortune 500 និត្យា មានបទ ពិសោធន៍ការងារជាង ៨ឆ្នាំ ក្នុងការគ្រប់គ្រង គណនេយ្យ សវនកម្ម គ្រប់គ្រងហានិភ័យ រួមទាំងការ ធ្វើផែនការ និងវិភាគហិរញ្ញវត្ថុ នៅក្នុងវិស័យជាច្រើន រួមទាំងវិស័យហិរញ្ញវត្ថុ ។

## ហេង សក្តា
### ប្រធាននាយដ្ឋានឥណទាន

លោក ហេង សក្តា ជាសមាជិកដែលបានធ្វើការយូរ ជាងគេជាមួយ ហ្វីស ហ្វាយនែន ។ ចាប់ផ្តើមដំបូង ជាមន្ត្រីរដ្ឋបាលឥណទាននៅឆ្នាំ ២០០៩ ពេលដែល ហ្វីស ហ្វាយនែន ទទួលបានអាជ្ញាប័ណ្ណ របស់ ខ្លួន ។ លោក សក្តា បានរីកចម្រើនជាមួយតួនាទី មួយចំនួន និងបានទទួលការតែងតាំងជាប្រធាន សាខាភ្នំពេញនៅឆ្នាំ ២០១៣ និងជាប្រធាននាយ-កដ្ឋានប្រតិបត្តិការនៅខែ ឧសភា ឆ្នាំ ២០១៥។ គាត់ មានចំណេះដឹងទូលំទូលាយអំពីក្រុងភ្នំពេញ ព្រោះ គាត់រស់នៅទីនេះពេញមួយជីវិតរបស់គាត់ តែគាត់ក៏ មានបទពិសោធន៍ ធ្វើដំណើរទៅក្រៅប្រទេសផងដែរ ។ លោក សក្តា ទទួលបានបរិញ្ញាបត្រពីរ គឺគណនេយ្យ ហិរញ្ញវត្ថុ និង ភាសាបារាំង ។ បច្ចុប្បន្នគាត់កំពុង បញ្ចប់អនុបណ្ឌិតគ្រប់គ្រងហានិភ័យ ផ្នែកធានា រ៉ាប់រង ហិរញ្ញវត្ថុ និងធនាគារ ។

## ភួន សេដ្ឋា
### ប្រធានផ្នែកលក់

លោក ភួន សេដ្ឋា បានទទួលបរិញ្ញាបត្រគ្រប់គ្រង ពីសាកលវិទ្យាល័យបាត់ដំបងក្នុងឆ្នាំ២០១២។ មុន មកកាន់ ហ្វីស ហ្វាយនែន គាត់បានបម្រើការនៅ វិសិនហ្វាន់រយៈពេល៥ឆ្នាំ២ខែមានតួនាទីជាប្រធាន សាខាខេត្ត ប្រធានសាខាស្រុក និងមន្ត្រីបម្រើ អតិថិជន។ គាត់ក៏បានបម្រើការជាគ្រូបវិទ្យានិង គណិតវិទ្យានៅអនុវិទ្យាល័យរយៈពេល៣ឆ្នាំដែរ។ គាត់បានចូលរួមជាមួយ ហ្វីស ហ្វាយនែនក្នុងខែ មិនា ឆ្នាំ២០១៣ជាប្រធានសាខា ហើយបន្ទាប់ មកក៏ត្រូវបានតែងតាំងជាប្រធានផ្នែកឥណទាន។

## វ៉េត វរលក្ខណ៍
### ប្រធានផ្នែកហិរញ្ញវត្ថុ

អ្នកស្រី វរលក្ខណ៍ មានបទពិសោធន៍ជាង៧ឆ្នាំ ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ ។ វរលក្ខណ៍ ធ្លាប់បម្រើការងារនៅតាមក្រុមហ៊ុនគណនេយ្យ ក្រុមហ៊ុនធានារ៉ាប់រង និងអាជីវកម្មទូទៅ ។ អ្នកស្រី ចូលបម្រើការងារនៅក្នុង ហ្វីស ហ្វាយនែន នា ឆ្នាំ២០១២។ វរលក្ខណ៍ បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រ ផ្នែកហិរញ្ញវត្ថុ និងធនាគារ អនុបណ្ឌិតផ្នែកគ្រប់គ្រង ពាណិជ្ជកម្ម និង បច្ចុប្បន្នកំពុងបន្តការសិក្សាថ្នាក់ ACCA ។

## សាំង វណ្ណឌី
### ប្រធានផ្នែកទីផ្សារ

លោក វណ្ណឌី បានទទួលបរិញ្ញាបត្រផ្នែកប្រព័ន្ធព័ត៌ -មានវិទ្យាគ្រប់គ្រង ពីសាកលវិទ្យាល័យជាតិគ្រប់-គ្រងក្នុងឆ្នាំ២០០២។ មុនមកចូលរួមជាមួយ ហ្វីស ហ្វាយនែន គាត់បានបំរើការជាអ្នកសម្របសម្រួល ផ្នែកទីផ្សារ និងទំនាក់ទំនងរយៈពេល ២ឆ្នាំ និង បន្ទាប់មកជាអ្នកគ្រប់គ្រងផ្នែកផលិតសម្ភារៈផ្សព្វ ផ្សាយជាង ៧ឆ្នាំ នៅវីសិនហ្វាន់ កម្ពុជា ដែលគាត់ ជាអ្នកគ្រប់គ្រង និងអភិវឌ្ឍន៍យុទ្ធសាស្ត្រប្រេនដ៏ និងយុទ្ធសាស្ត្រទំនាក់ទំនងទីផ្សារ។ លោក វណ្ណឌី ក៏មានបទពិសោធន៍ជាច្រើនឆ្នាំខាងផ្នែកផ្សព្វផ្សាយ និងអង្គការអន្តរជាតិផងដែរ។ គាត់ចូលរួមជាមួយ ហ្វីស ហ្វាយនែន ក្នុង ខែមីនា ឆ្នាំ២០១៦ ជា ប្រធានផ្នែកទីផ្សារ។

# គណៈគ្រប់គ្រង



## លឹម សូហ៊ីយ៉ា ហ្វាដែត
### ប្រធានផ្នែកអភិវឌ្ឍន៍ពាណិជ្ជកម្ម

អ្នកស្រី ហ្វាដែត បានបញ្ចប់បរិញ្ញាបត្រសេដ្ឋកិច្ច ជំនាញផ្នែកគ្រប់គ្រង និងបច្ចុប្បន្ននេះកំពុងតែបន្តថ្នាក់អនុបណ្ឌិតនៅ សាកលវិទ្យាល័យ Limkokwing ជំនាញហិរញ្ញវត្ថុ។ មុនមកចូលរួមជាមួយ ហ្វីស ហ្វាយនែន ធ្វើជាប្រធានផ្នែកអភិវឌ្ឍន៍ពាណិជ្ជកម្ម នាឆ្នាំ២០១៦ អ្នកស្រីបានចំណាយពេល៥ឆ្នាំធ្វើការនៅក្នុងប្រទេសកម្ពុជាក្នុងវិស័យហិរញ្ញវត្ថុ ក៏ដូចជា វិស័យឧបករណ៍អេឡិចត្រូនិច ហើយបន្ទាប់មកក៏បានចំណាយពេល៤ឆ្នាំធ្វើការជាអ្នកស្ម័គ្រចិត្តផ្នែកមូលនិធិនិងសង្គមកិច្ចនៅប្រទេសសិង្ហបុរី។ អ្នកស្រីមានជំនាញផ្នែក លក់ ទីផ្សារ ទំនាក់ទំនង ការប្រមូលមូលនិធិ គ្រប់គ្រងគម្រោង និងទំនាក់ទំនងសាធារណៈ។



## ច្រឹក ស៊ីណោត
### ប្រធានផ្នែកព័ត៌មានវិទ្យា

លោក ស៊ីណោត បានបម្រើការអស់រយៈពេលជាង១០ឆ្នាំ ក្នុងកិច្ចការស្ថាបនា និងអនុវត្តប្រព័ន្ធកុំព្យូទ័រ អនុវត្តសុវត្ថិភាពព័ត៌មានវិទ្យា គ្រប់គ្រងប្រព័ន្ធព័ត៌មាន យុទ្ធសាស្ត្រព័ត៌មានវិទ្យា និងអនុវត្តគំរោងជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារ ។ គាត់បានចូលរួម ហ្វីស ហ្វាន់នែនជាប្រធានគ្រប់គ្រងព័ត៌មានវិទ្យា នាខែមេសា ឆ្នាំ២០១៦។ មុនមកកាន់ ហ្វីស ហ្វាយនែន គាត់ជាប្រធានគាំទ្រកម្មវិធីព័ត៌មានវិទ្យា ដែលមានតួនាទីសម្របសម្រួល រវាងបុគ្គលិកបច្ចេកទេសព័ត៌មានវិទ្យានិងបុគ្គលិកផ្នែកអាជីវកម្ម នៅអម្រឹតរយៈពេល១ឆ្នាំ និងធ្លាប់ជាប្រធានគាំទ្រកម្មវិធីនិងបច្ចេកទេសនៅ វិសិនហ្វាន់កម្ពុជា។ គាត់បានទទួលបរិញ្ញាបត្រព័ត៌មានវិទ្យា ពីសាកលវិទ្យាល័យមួយនៅក្រុងភ្នំពេញ។



## ស្រេង ស្រីពៅ
### ប្រធានផ្នែក រដ្ឋបាលនិងធនធានមនុស្ស

អ្នកស្រី ស្រីពៅ បានទទួលបរិញ្ញាបត្រផ្នែកគណនេយ្យ និងអនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវកម្ម។ អ្នកស្រី មានបទពិសោធន៍ជាង៨ឆ្នាំ ផ្នែកធនធានមនុស្ស និងរដ្ឋបាល ទាំងក្នុងស្ថានប័នមិនរកប្រាក់ចំណេញ និងស្ថាប័នឯកជន។ មុនមកចូលរួមជាមួយ ហ្វីស ហ្វាយនែន ជាប្រធានផ្នែករដ្ឋបាលនិងធនធានមនុស្សនៅ ខែតុលា ឆ្នាំ២០១៦ អ្នកស្រីបានបំរើការជាមន្ត្រីធនធានមនុស្ស និងជាអ្នកសម្របសម្រួលនៅមន្ទីរពេទ្យព្រះសីហនុ មជ្ឈមណ្ឌលនៃសេចក្តីសង្ឃឹមពិភពលោក ដែលអ្នកស្រីមានតួនាទីជាអ្នករើសបុគ្គលិកគ្រប់គ្រងការវាយតម្លៃការងារ ការហ្វឹកហាត់ និងអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានធនធានមនុស្ស ទំនាក់ទំនងបុគ្គលិក អត្ថប្រយោជន៍បុគ្គលិក និងសំណង។



## ឈូ សំបូរ
### ប្រធានសវនកម្មផ្ទៃក្នុង

លោក សំបូរ មានបទពិសោធន៍ជាង៦ឆ្នាំក្នុងការងារធានារ៉ាប់រង និងជាសវនករ។ គាត់បានចាប់ផ្តើមអាជីពរបស់គាត់ដំបូងនៅ PriceWaterhouse Coopers (PwC) កម្ពុជា ធ្វើជាអ្នកជំនួយការសវនករ បន្ទាប់មកជាសវនករជាន់ខ្ពស់រយៈពេល៤ឆ្នាំ ចាប់តាំងពីឆ្នាំ២០០៧។ បន្ទាប់មកលោកក៏ផ្លាស់មក ហ្វីស ហ្វាយនែន ធ្វើជាសវនករជាន់ខ្ពស់ និងបន្ទាប់មកជាប្រធានគ្រប់គ្រងសវនករ បន្ទាប់ពីបានបញ្ចប់ការសិក្សាអនុបណ្ឌិតរយៈពេល២ឆ្នាំផ្នែកហិរញ្ញវត្ថុពីប្រទេស ញូវហ្សេលេន។ លោក សំបូរ បានទទួលបរិញ្ញាបត្រនិងអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ ហើយបច្ចុប្បន្ននេះកំពុងតែបន្តរយក ACCA/CPA។



## ស៊ាន ម៉េងសែ
### ប្រធានផ្នែកបណ្តុះបណ្តាល និងអភិវឌ្ឍ

ម៉េងសែ មានការរីកចម្រើនខ្ពស់ក្នុងអាជីពការងារ ។ លោកបានប្រលូកចូលក្នុងវិស័យការងារបានជាង១០ឆ្នាំ ដោយចាប់ផ្តើមពីកម្រិតបុគ្គលិកធម្មតា រហូតដល់កម្រិតគ្រប់គ្រងក្នុងផ្នែកបណ្តុះបណ្តាល និងអភិវឌ្ឍ និងផ្នែកគ្រប់គ្រងធនធានមនុស្ស ដោយលោកមានបទពិសោធន៍ និងជំនាញពាក់ព័ន្ធនឹងផ្នែកជ្រើសរើសបុគ្គលិក បង្កើតគោលនយោបាយធនធានមនុស្ស រដ្ឋបាលបុគ្គលិក សម្របសម្រួលកិច្ចការធនធានមនុស្ស សំណងទូទាត់។ល។ លោកមានអត្តចរិកល្អប្រសើរ មានភាពអត់ធ្មត់ និងការតាំងចិត្តខ្ពស់។ អំពីការសិក្សា លោកបានទទួលអាហារូបករណ៍កម្រិតបរិញ្ញាបត្រពីសាកលវិទ្យាល័យជាតិគ្រប់គ្រងក្នុងឆ្នាំ២០០០ និងបានបញ្ចប់បរិញ្ញាបត្រផ្នែកគ្រប់គ្រងក្នុងឆ្នាំ២០០៤ និងបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងក្នុងឆ្នាំ ២០០៩។



## អ៊ិន ឈួន
### ប្រធានសាខាខេត្តបាត់ដំបង

លោក ឈួន បានទទួលបរិញ្ញាបត្រផ្នែកធនាគារ និងហិរញ្ញវត្ថុពីសាកលវិទ្យាល័យគ្រប់គ្រង និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំ២០១២។ មុនចូលមក ហ្វីស ហ្វាយនែន គាត់បានបម្រើការនៅ វិសិនហ្វាន់ រយៈពេល៨ឆ្នាំ ជាអ្នកគ្រប់គ្រងជាន់ខ្ពស់សាខាស្រុក មន្ត្រីជាន់ខ្ពស់ផ្នែកហានិភ័យ មន្ត្រីជាន់ខ្ពស់ផ្នែកគុណភាពធានារ៉ាប់រង និងមន្ត្រីឥណទាន។ លោក ឈួន មានតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងការរីកចម្រើនផលបត្រឥណទាន និងការគ្រប់គ្រងហានិភ័យរបស់សាខា។ គាត់បានចូលរួមជាមួយ ហ្វីស ហ្វាយនែន ក្នុងឆ្នាំ២០១៥ ជាប្រធានក្រុមមន្ត្រីប្រឹក្សាឥណទាន និងបន្ទាប់មកជាប្រធានសាខា។

# គណៈគ្រប់គ្រង



## ឃើង ប៊ុនហួរ

### ប្រធានសាខាខេត្តសៀមរាប

លោក ប៊ុនហួរ បានចាប់ផ្តើមការងារជាប្រធានសាខានៅ ហ្វីស ហ្វាយនែន ក្នុងខែកុម្ភៈ ឆ្នាំ ២០១៧ ។ មុននេះ លោកមានបទពិសោធន៍ជាង ៨ឆ្នាំ នៅអិលអូអិលស៊ី ជាប្រធានសាខា ប្រធានផ្នែកមន្ត្រីឥណទាន និងមន្ត្រីឥណទាន ដែលក្នុងតួនាទីទាំងនោះគាត់ទទួលខុសត្រូវទាំងទងទៅនឹងបង្កើនចំនួនឥណទាន ការគ្រប់គ្រងហានិភ័យ និងគ្រប់គ្រងបុគ្គលិកនៅក្នុងសាខា ។ គាត់បានបញ្ចប់បរិញ្ញាបត្រផ្នែកគ្រប់គ្រងនៅសាកលវិទ្យាល័យអាស៊ីអាគ្នេយ៍នៅក្នុងឆ្នាំ ២០១១ ។



## ដាំង ប៉ូ

### ប្រធានសាខាខេត្តកំពត

លោក ប៉ូ មានបទពិសោធន៍ជាង ១០ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ។ ក្នុងអាជីពការងាររបស់គាត់គឺចាប់ផ្តើមពីតួនាទីជាបុគ្គលិកនឹងអភិវឌ្ឍរហូតដល់តំណែងអ្នកគ្រប់គ្រង ។ លោកបានបម្រើការនៅ អិលអូអិលស៊ី អស់រយៈពេលជិត ១០ឆ្នាំក្នុងនោះលោកបានកាន់តួនាទីជាប្រធានសាខាបានរយៈពេលជាច្រើនឆ្នាំមុនពេល ដែលលោកចូលមកបម្រើការនៅ ហ្វីស ហ្វាយនែន ក្នុងឆ្នាំ ២០១៧ ។ លោកបានបញ្ចប់បរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ និងធនាគារពីសាកលវិទ្យាល័យឯកទេសកម្ពុជានៅឆ្នាំ ២០១៦ ។



## លី ប៊ុនលាង

### ប្រធានសាខាខេត្តកំពង់ចាម

លោក ប៊ុនលាង មានបទពិសោធន៍ជាង ១០ ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ។ លោកចាប់ផ្តើមការងារក្នុងវិស័យនេះពីតួនាទីជាមន្ត្រីឥណទាន រហូតដល់ប្រធានសាខាខេត្ត ក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ ។ លោកបានចូលបម្រើការនៅ ហ្វីស ហ្វាយនែន ក្នុងខែសីហា ឆ្នាំ ២០១៧ ជាប្រធានសាខាខេត្ត។ លោក លី ប៊ុនលាង បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ នៅសកលវិទ្យាល័យបៀលប្រាយ (ភ្នំពេញ)នៅ ឆ្នាំ២០០៦ ជំនាញគណនេយ្យ និងហិរញ្ញវត្ថុ ។





## ទឹម ហោះ

### ប្រធានសាខាពោធិ៍សែនជ័យ

លោក ទឹម ហោះ មានបទពិសោធន៍ជាង ១០ ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ។ គាត់បានចូលបម្រើការងារជាមួយ ហ្វីស ហ្វាយនែន ជាប្រធានសាខាក្នុងខែមិថុនា ឆ្នាំ២០១៧ ។ មុនពេលនេះ គាត់បានបម្រើការនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ អស់រយៈពេល ៨ឆ្នាំ ពីតួនាទីជាមន្ត្រីឥណទាន រហូតដល់ប្រធានអនុសាខា។ លោក ទឹម ហោះ បានបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគ្រប់គ្រងអាជីវកម្មពីសាកលវិទ្យាល័យជាតិគ្រប់គ្រងក្នុងឆ្នាំ ២០១៦ ។



## ឡេង សេងហ៊ត

### ប្រធានសាខាចំការមន ឬស្សីកែវ

លោក ឡេង សេងហ៊ត មានបទពិសោធន៍ជាង ១០ ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងក្រុមហ៊ុនឯកជនដទៃទៀត។ មុនពេលចូលបម្រើការងារជាមួយ ហ្វីស ហ្វាយនែន ជាប្រធានសាខា ក្នុងខែមីនា ឆ្នាំ២០១៧ គាត់បានបម្រើការនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ LOLC អស់រយៈពេលជាង ៦ ឆ្នាំ។ លោក ឡេង សេងហ៊ត បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញគ្រប់គ្រងទូទៅ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងឆ្នាំ ២០១៦ ។

